១៦.១.១៤ ជំងឺរោមសេះ....................................................................... ៤៨៥
១៦.១.១៥. ជំងឺប្រេះមុខចៀរ....................................................................... ៤៨៥
១៦.១.១៦. ជំងឺស្ងួតមុខចៀរ ....................................................................... ៤៨៦
១៦.១.១៧. ជំងឺផ្សិតស ....................................................................... ៤៨៧
១៦.១.១៨. ជំងឺផ្សុតខ្មៅ ....................................................................... ៤៨៧
១៦.១.១៩. ជំងឺពុកមុខចៀរ ....................................................................... ៤៨៨
១៦.១.២០. ជំងឺភ្នែកចាប....................................................................... ៤៨៩
១៦.១.២១. ជំងឺផ្សិតអង់ត្រាក់ណូស ....................................................................... ៤៩០
១៦.១.២២. ជំងឺផ្សិតម្សៅ ....................................................................... ៤៩០
១៦.១.២៣. ជំងឺក្រៀមកន្ទុយស្លឹក ....................................................................... ៤៩១
១៦.១.២៤ ជំងឺរលាកស្លឹក ....................................................................... ៤៩១
១៦.១.២៥. ជំងឺក្រៀមស្លឹកភីថប់ហ្សូរ៉ា....................................................................... ៤៩២
**១៦.២ សត្វល្អិតចង្រៃលើដំណាំកៅស៊ូ**....................................................................... ៤៩២
១៦.២.១. សត្វកណ្ដៀរ ....................................................................... ៤៩២

## ផ្នែកទី១៧ ស្មៅចង្រៃ

**១៧.១ ក្រុមស្មៅស្លឹកធំ** ....................................................................... ៤៩៣
១៧.១.១. ស្មៅទឹក ....................................................................... ៤៩៣
១៧.១.២. ស្មៅគោក....................................................................... ៤៩៣
១៧.១.៣. ទន្ទ្រានខេត្តស្វាយ....................................................................... ៤៩៤
១៧.១.៤. ស្មៅជើងបង្កង....................................................................... ៤៩៥
១៧.១.៥. ផ្ទីបន្លា....................................................................... ៤៩៥
១៧.១.៦. ស្មៅស្លាបទាញី....................................................................... ៤៩៦
១៧.១.៧. ស្មៅស្លាបទាឈ្មោល ....................................................................... ៤៩៧
១៧.១.៨. មុខឈ្មាង ....................................................................... ៤៩៧

១៧.២.៤. ស្មៅបែកក្បាលគ្មានកន្ទុយ ..... ៥៤៨
១៧.២.៥. ស្មៅបែកក្បាលមានកន្ទុយ ..... ៥៤៩
១៧.២.៦. ស្មៅកន្ទុយដំរី ..... ៥៤៩
១៧.២.៧. ស្មៅជើងក្រាស់ ..... ៥៥០
១៧.២.៨. ស្បូវឃ្លាំង ..... ៥៥១
១៧.២.៩. ស្មៅចំពុះទា ..... ៥៥១
១៧.២.១០. ស្មៅរនាម ..... ៥៥២
១៧.២.១១. ស្មៅក្អុយក្ងោក ..... ៥៥៣
១៧.២.១២. ស្មៅបំពង់ ..... ៥៥៣
១៧.២.១៣. ស្មៅរពាក់ទឹកវារ ..... ៥៥៤
១៧.២.១៤. ស្មៅរពាក់ទឹកឈរ ..... ៥៥៥
១៧.២.១៥. ស្មៅរមាស់ ..... ៥៥៥
១៧.២.១៦. ស្មៅបារាំង ..... ៥៥៦
១៧.២.១៧. ស្មៅគោ ..... ៥៥៧
១៧.២.១៨. ស្មៅសំបុកមាន់ ..... ៥៥៧
១៧.២.១៩. ស្មៅទន្សោង ..... ៥៥៨
១៧.២.២០. ស្បូវភ្លាំង ..... ៥៥៩
១៧.២.២១. ត្រែង ..... ៥៦០

**១៧.៣. ក្រុមកក់** ..... ៥៦០
១៧.៣.១. កក់ផ្កាកញ្ចុំ ..... ៥៦០
១៧.៣.២. កក់ឆ័ត្រតូច ..... ៥៦១
១៧.៣.៣. ស្មៅក្រវាញជ្រូក ..... ៥៦២
១៧.៣.៤. កក់ភ្នែកក្ដាមតូច ..... ៥៦៣
១៧.៣.៥. កក់ភ្នែកក្ដាមធំ ..... ៥៦៣
១៧.៣.៦. កក់ជ្រុងឆ័ត្រធំ ..... ៥៦៤

**តារាងឧបសម្ព័ន្ធ** ..... ៥៦៥
**ឯកសារយោង** ..... ៥៨៧

# ផ្នែកទី១
# ដំណាំស្រូវ

# ១. ដំណាំស្រូវ

## ១.១ សត្វល្អិតចង្រៃលើដំណាំស្រូវ

### ១.១.១. ដង្កូវហ្វូង

ឈ្មោះទូទៅជាភាសាខ្មែរ: ដង្កូវហ្វូង

ឈ្មោះទូទៅជាភាសាអង់គ្លេស: **Armyworm**

ឈ្មោះវិទ្យាសាស្ត្រ: ***Spodoptera mauritia*** **Boisduval,** ***Spodoptera litura*** **F.** និង ***Mythimna separata*** **Walker**

គ្រួសារ: **Noctuidae**

ការពិពណ៌នា:



រូបភាព: ដង្កូវហ្វូងបំផ្លាញលើដំណាំស្រូវ

ប្រភព: IRRI



រូបភាព: មេអំបៅរបស់ដង្កូវហ្វូង

ប្រភព: Amy Carmichael, Queensland University of Technology

ជាប្រភេទសត្វល្អិតចង្រៃដែលបំផ្លាញលើដំណាំស្រូវ។ កូនដង្កូវមានពណ៌ខៀវ ហើយប្រែទៅជាពណ៌ត្នោត និងមានស្នាមឆ្នូតនៅលើខ្នង។ ដឹកឌឿមានពណ៌ត្នោត និងសម្ងំលាក់ខ្លួនទៅក្នុងដីជម្រៅប្រមាណ ២ ស.ម។ មេអំបៅពេញវ័យមានពណ៌ត្នោត មានស្នាមអ៊ុចៗនៅលើស្លាបផ្នែកខាងក្រៅ ឯស្លាបខាងក្នុងមានពណ៌ព្រលែត។ ឈ្មោះមេអំបៅ និងដង្កូវ បានមកពីរបៀបនៃការរស់នៅដែលមានលក្ខណៈជាហ្វូង។ កូនដង្កូវស៊ីចំណីដោយកាត់ផ្នែកខាងចុងនៃស្លឹក, គែមស្លឹក, ស្លឹក និងគល់របស់ដើម ហើយក៏អាចកាត់កួរស្រូវផងដែរ។

ដង្កូវហ្វូងមានរយៈពេល ៦០ថ្ងៃ: (ពង......៩........ដង្កូវ........២៨.........ដឹកឌឿ........១៦.......មេ........៧.........ពង)



### ១.១.២. ស្រឹងខ្មៅ

ឈ្មោះទូទៅជាភាសាខ្មែរ : ស្រឹងខ្មៅ

ឈ្មោះទូទៅជាភាសាអង់គ្លេស : **Black bug**

ឈ្មោះវិទ្យាសាស្ត្រ : *Scotinophara coarctata*

គ្រួសារ : **Pentatomidae**

ការពិពណ៌នា :

ស្រឹងខ្មៅ ទម្លាក់ពងដាក់ផ្នែកខាងក្រោមនៃស្លឹកជាប់ផ្ទៃទឹក ដោយពងជាជួរ ចាប់ពី ២-៤ជួរ។ កូនទើបញាស់មានពណ៌ត្នោតថ្លា ស្រឹងខ្មៅពេញវ័យ មានរាងស្តើង និងមានពណ៌ត្នោតក្រម៉ៅ ឬពណ៌ខ្មៅនៅពេលមានអាយុចំណាស់បន្តិច។ នៅពេលថ្ងៃស្រឹងខ្មៅពេញវ័យច្រើនលាក់ខ្លួននៅផ្នែកខាងគល់នៃដើម ហើយនៅពេលយប់វាធ្វើការបំលាស់ទីមកផ្នែកខាងចុងនៃផ្ទៃស្លឹក។ សង្កើចខ្មៅចូលចិត្តសំណើម និងទាមទាឱ្យមានសំណើមនៅរដូវរាំងស្ងួត។




ក្រោយពងបាន ៤-៧ថ្ងៃ ទើប កូនចាប់ផ្តើមញាស់។ មុននឹងញាស់ពងរបស់វាប្រែពណ៌ពីពណ៌បៃតងទៅជាពណ៌លឿងទុំ។ កូនស្រឹងខ្មៅមានពណ៌ត្នោត ឬលឿង និងមានចំណុចខ្មៅៗហើយមានដងខ្លួនប្រវែង ២-៨មម។ កូនទើបញាស់មុនដំបូងវារកស៊ីនៅជិតពងហើយបន្ទាប់មកទៀតពួកវារកស៊ីនៅគល់ស្រូវតែម្តង។ ពីកូនទៅពេញវ័យមានរយៈពេល២៩-៣៥ថ្ងៃ។ មេស្រឹងខ្មៅមានពណ៌ខ្មៅមានប្រវែង ៨-៩មម។ វដ្តជីវិតរបស់ស្រឹងខ្មៅគិតពីពេលពងរហូតដល់ពេញវ័យមានរយៈពេល៣៣-៤១ថ្ងៃ ហើយមេស្រឹងខ្មៅអាចរស់បានរហូតដល់ទៅ៧ខែ។



រូបភាព: ស្រឹងខ្មៅ និងពងរបស់វា
ប្រភព: Wendell L. Morrill



រូបភាព: ស្រឹងខ្មៅ និងពងរបស់វាទើបញាស់
ប្រភព: Wendell L. Morrill



រូបភាព : ពងស្រឹងខ្មៅ និងកូន ទើបញាស់
ប្រភព : Wendell L. Morrill

### ១.១.៣. ដង្កូវស៊ីរូងដើម

**ឈ្មោះទូទៅជាភាសាខ្មែរ :** ដង្កូវស៊ីរូងដើម

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** **Stem borer**

**ឈ្មោះវិទ្យាសាស្ត្រ :** ***Scirpophaga incertulas*** **និង** ***Sesamia inferens***

**គ្រួសារ :** Pyrausdtidae

ការពិពណ៌នា :

ដង្កូវស៊ីរូងដើម គឺជាសត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវ ដែលអាចកើតមាននៅគ្រប់បរិស្ថានដំណាំស្រូវ។ មេអំបៅដង្កូវស៊ីរូងដើមមាន០៤ប្រភេទសំខាន់ៗ និងមានវដ្តជីវិតរបស់ពួកវាមានរយៈពេលប្រហែលគឺ ៤៦ថ្ងៃ។ ពងរបស់ដង្កូវស៊ីរូងដើមមានលក្ខណៈជាកញ្ចុំដែលមានចំនួន ៥០-២៥០ពងស្ថិតនៅលើផាងស្លឹក ឬនៅចន្លោះស្រទាប់ស្លឹក និងដើម។ ពងមានពណ៌ពីសទៅលឿង និងប្រែពណ៌ទៅជាខ្មៅនៅពេលជិតញាស់ (មានរោមឆ្មាៗគ្របការពារពីលើ)។ ដង្កូវពេលញាស់ភ្លាមមានពណ៌ស និងប្រែទៅជាពណ៌ស៊ីជម្ពូ ឬលឿងត្នោតទៅតាមប្រភេទនៅថ្ងៃបន្ទាប់ៗទៀត។ ដង្កូវពេញរូបរាងមានប្រវែងខ្លួនពី២,៥សម ទៅ ៣,៥សម (រស់នៅក្នុងដើមស្រូវ)។ ដឹកឡើរបស់ដង្កូវស៊ីរូងដើមរស់នៅគល់នៃដើមស្រូវមានពណ៌លឿងចាស់ ឬពណ៌ត្នោត។ មេអំបៅរបស់ដង្កូវស៊ីរូងដើមទុំនៅលើស្លឹក ឬលើដើមស្រូវ និងស្មៅនៅក្បែរស្រែ។

**ប្រភេទមេអំបៅដង្កូវស៊ីរូងដើម (ប្រភព : អគ្គនាយកដ្ឋានកសិកម្ម)**



មេអំបៅដង្កូវស៊ីរូងដើមញីមានពណ៌លឿង(មានចំណុចខ្មៅពីរជាសំគាល់)



មេអំបៅដង្កូវស៊ីរូងដើមឈ្មោលមានពណ៌ត្នោតស្រាល(ចំណុចខ្មៅតូចៗមួយជួរចុងស្លាប)



មេអំបៅដង្កូវស៊ីរូងដើមមានពណ៌ស (គ្មានចំណុចទេ តែមានរោមវែងលើក្បាល)



មេអំបៅដង្កូវស៊ីរូងដើមឆ្នូតមានពណ៌ត្នោតស្រាល និងមានចំណុចខ្មៅមួយចំនួននៅចុងស្លាប



មេអំបៅដង្កូវស៊ីរូងដើមពណ៌ផ្កាឈូកមានពណ៌ត្នោតស្រាល និងរោមក្បាលច្រើន




រូបភាព : វដ្តជីវិតរបស់ដង្កូវស៊ីរូងដើម
ប្រភព : អគ្គនាយកដ្ឋានកសិកម្ម




រូបភាព : លក្ខណៈរូបរាងរបស់ដង្កូវស៊ីរូងដើម
ប្រភព : Dennis S. Hill



រូបភាព : លក្ខណៈរូបរាងដង្កូវ និងដឹកឌឿ
ប្រភព : Merle Shepard



រូបភាព: មេអំបៅដង្កូវស៊ីរូងដើម
ប្រភព: Merle Shepard



រូបភាព: រោគសញ្ញាបំផ្លាញដោយដង្កូវស៊ីរូងដើម
ប្រភព : IRRI

ដង្កូវបំផ្លាញដំណាំស្រូវដោយស៊ីផ្នែកខាងក្នុងនៃដើមស្រូវដើម្បីចិញ្ចឹមជីវិតដែលធ្វើឱ្យខូចប្រព័ន្ធក្នុងដើមស្រូវ។ ការបំផ្លាញរបស់ដង្កូវនេះមានរយៈពេលពី ២២-៣០ថ្ងៃ។ ដង្កូវស៊ីរូងដើមក្នុងចំណោមសត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវយ៉ាងខ្លាំងជាងគេ ។

### ១.១.៤. ដង្កូវបំពង់កាត់ស្លឹក

ឈ្មោះទូទៅជាភាសាខ្មែរ : ដង្កូវបំពង់កាត់ស្លឹក
ឈ្មោះទូទៅជាភាសាអង់គ្លេស : Case worm
ឈ្មោះវិទ្យាសាស្ត្រ : *Nymphula depunctalis* Guenee
គ្រួសារ : Crambidae

ការពិពណ៌នា :

ដង្កូវបំពង់កាត់ស្លឹក គឺជាសត្វល្អិតចង្រៃដែលមានជីវិតរស់នៅពាក់កណ្តាលលើគោក និងជីវិតពាក់កណ្តាលរស់នៅក្នុងទឹក។ ក្នុងដំណាក់កាលដង្កូវ វាស៊ីបំផ្លាញស្លឹកស្រូវខ្ចីៗរួចកាត់ស្លឹកស្រូវរុំមូរខ្លួនរបស់វាជាបំពង់ទម្លាក់ខ្លួនមកលើផ្ទៃទឹកហើយបណ្តែតខ្លួនតាមផ្ទៃទឹក។ នៅពេលយប់វាតោងឡើងដើមស្រូវហើយបន្តការស៊ីស្លឹកដោយបកយកកោសិកាស្លឹកពណ៌បៃតងដោយបន្សល់ទុកតែជាលិកាស្លឹកពណ៌សរដូចក្រដាស់។




រូបភាព : វដ្តជីវិតរបស់ដង្កូវបំពង់កាតស្លឹក
ប្រភព : អគ្គនាយកដ្ឋានកសិកម្ម




រូបភាព : មេអំបៅ និងសំបុកដង្កូវ (គំនូរ)
ប្រភព : Dennis S. Hill



រូបភាព : មេអំបៅដង្កូវបំពង់កាត់ស្លឹក
ប្រភព : IRRI

ការបំផ្លាញរបស់ដង្កូវកាត់បំពង់កាត់ស្លឹកមាន២យ៉ាងគឺ ទី១៖ កូនដង្កូវកាត់ស្លឹកស្រូវបង្កើតជាបំពង់ដើម្បីលាក់ខ្លួនបង្កើតជាស្នាមដាច់ស្លឹក។ ទី២៖ វាកោសស៊ីស្លឹកស្រូវបង្កើតជាស្នាមសៗ និងបើពិនិត្យអោយជិតមានសណ្ឋានដូចកាំជណ្តើរ។

### ១.១.៥. ដង្កូវមូរស្លឹក

ឈ្មោះទូទៅជាភាសាខ្មែរ : ដង្កូវមូរស្លឹក
ឈ្មោះទូទៅជាភាសាអង់គ្លេស : Rice leaf folder
ឈ្មោះវិទ្យាសាស្ត្រ : *Cnaphalocrocis medinalis, Marasmia patnalis* និង *Marasmia exigua*
គ្រួសារ : Crambidae

ការពិពណ៌នា :

ដង្កូវមូរស្លឹក គឺជាសត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវដែលអាចកើតមាននៅគ្រប់បរិស្ថានដំណាំស្រូវ។ មេអំបៅដង្កូវមូរស្លឹកមាន៣ប្រភេទសំខាន់ៗ ហើយវដ្តជីវិតរបស់ពួកវាមានរយៈពេលពី ៣០-៣៥ថ្ងៃ។ ពងមានរាងមូលជាប់ទៅនឹងស្លឹក។ នៅដំណាក់កាលដំបូង ដង្កូវមានពណ៌លឿងស្រាល បន្ទាប់មកប្រែពណ៌ជាបៃតងលឿង ហើយក្បាលមាន

ពណ៌ត្នោតក្រម៉ៅ។ ដឹកខឿមានពណ៌ត្នោតព័ទ្ធជុំវិញដោយសូត្រ និងស្ថិតនៅក្នុងរមូរស្លឹក។ មេអំបៅមានពណ៌ត្នោតលឿង ដោយមានចំណុចឆ្នូតខ្មៅៗនៅលើស្លាប។ មេអំបៅញី១ក្បាលអាចពងបាន ៥០-៣០០ពងក្នុងរយៈពេលចន្លោះពេល៣-១០ថ្ងៃ។




រូបភាព: វដ្តជីវិតរបស់ដង្កូវមូរស្លឹក
ប្រភព: អគ្គនាយកដ្ឋានកសិកម្ម



រូបភាព: ដង្កូវមូរស្លឹក និងរោគសញ្ញានៃការបំផ្លាញ
ប្រភព: IRRI



មេអំបៅ *Cnaphalocrocis medinalis*



មេអំបៅ *Marasmia patnalis*



មេអំបៅ *Marasmia exigua*

រូបភាព: មេអំបៅដង្កូវមូរស្លឹក
ប្រភព: Merle Shepard

### ១.១.៦. មមាចត្នោត

ឈ្មោះទូទៅជាភាសាខ្មែរ : មមាចត្នោត
ឈ្មោះទូទៅជាភាសាអង់គ្លេស : Brown planthopper
ឈ្មោះវិទ្យាសាស្ត្រ : *Nilaparvata lugens* Stal
គ្រួសារ : Delphacidae

ការពិពណ៌នា:

មមាចត្នោតធ្វើការបំផ្លាញទាំងស្រែដែលប្រើប្រាស់ប្រព័ន្ធស្រោចស្រព និងស្រែដែលទទួលរបបទឹកភ្លៀង។ វាអាចកើតមានច្រើនបំផុត នៅពេលដែលមានការប្រើប្រាស់ថ្នាំកសិកម្មមិនបានសមស្របទៅតាមបច្ចេកទេសណែនាំ។ វដ្តជីវិតរបស់មមាចត្នោតមានរយៈពេល ៣៥ថ្ងៃ។ មមាចពេញវ័យអាចរស់បានរយៈពេល ១០-២០ថ្ងៃ និងមាន២រូបរាង គឺ មមាចស្លាបខ្លី និងមមាចស្លាបវែង។ មមាចស្លាបខ្លីមានវត្តមានក្នុងស្រែពិសេសមុនដំណាក់កាលស្រូវចេញផ្កា។




រូបភាព : វដ្តជីវិតរបស់មមាចត្នោត
ប្រភព : អគ្គនាយកដ្ឋានកសិកម្ម



រូបភាព : កូនមមាចត្នោត
ប្រភព : IRRI



រូបភាព : មេមមាចត្នោត
ប្រភព : IRRI

### ១.១.៧. មមាចបៃតង

**ឈ្មោះទូទៅជាភាសាខ្មែរ :** **មមាចបៃតង**
**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Green leafhopper
**ឈ្មោះវិទ្យាសាស្ត្រ :** *Nephotettix malayanus* **និង** *Nephotettix virescens.*
**គ្រួសារ :** Cicadellidae

ការពិពណ៌នា :

មមាចខៀវពេញវ័យមានប្រវែងដងខ្លួន ៣-៥ម.ម ហើយមានពណ៌បៃតងភ្លឺរលោង និងមានស្នាមដុំៗពណ៌ខ្មៅដែលអាចប្រែប្រួលបាន។ មមាចខៀវញីពងដាក់ក្នុងស្រទបស្លឹក ឬទ្រនុងស្លឹកជាកញ្ចុំរាងដូចស្និតចេកប្រមាណ ៨-១៦ពង ដោយប្រដាប់បញ្ចេញពងរបស់វា។ ពងថ្មីៗរបស់វាមានពណ៌ស ឬលឿងព្រលែត ប៉ុន្តែបន្ទាប់មកទៀតវាក្លាយជាពណ៌ត្នោត និងមានចំណុចពណ៌ក្រហម។ កូនញាស់របស់ថាមានប្រាំដំណាក់កាល និងមានស្នាម ឬចំណុចដែលអាចប្រែប្រួលបាន។ មមាចខៀវមានវត្តមានសឹងតែគ្រប់ទីកន្លែង។ មមាចខៀវនេះជាភ្នាក់ងារចម្លងជំងឺវីរុសលើដំណាំស្រូវយ៉ាងសំខាន់ដូចជា ជំងឺក្រិនតឿ ជំងឺទង់គ្រោ និងជំងឺតឿលឿង។



១.១.៨. មមាចពព្រុស

ឈ្មោះទូទៅជាភាសាខ្មែរ : មមាចពព្រុស

ឈ្មោះទូទៅជាភាសាអង់គ្លេស : Zigzag leafhopper

ឈ្មោះវិទ្យាសាស្ត្រ : *Recilia dorsalis* (Motschulsky)

គ្រួសារ : Cicadellidae

ការពិពណ៌នា :

មមាចព្រុសជាសត្វល្អិតដែលជញ្ជក់យករុក្ខរសពីដំណាំស្រូវ។ ស្លាបរបស់មមាចពព្រុសពេញវ័យមានគំនូសរាងជាអក្សរហ្សែត "Z" ជាជំណាំ។ កូនញាស់របស់វាមានពណ៌ត្នោតលឿង។ មមាចពព្រុសជាភ្នាក់ងារចម្លងជំងឺទង់គ្រោ និងជំងឺវីរុសសំខាន់ៗដ៏ទៃទៀតលើដំណាំស្រូវ។ វិធានការគ្រប់គ្រងមមាចពព្រុសមានលក្ខណៈប្រហាក់ប្រហែលគ្នា នឹងវិធានការគ្រប់គ្រងមមាចខៀវដែរ។



១.១.៩. ស្រឹងជញ្ជក់ទឹកដោះ

ឈ្មោះទូទៅជាភាសាខ្មែរ : ស្រឹងជញ្ជក់ទឹកដោះ

ឈ្មោះទូទៅជាភាសាអង់គ្លេស : Rice bug

ឈ្មោះវិទ្យាសាស្ត្រ : *Leptocorisa oratorius* F. និង *Leptocorisa acuta* Thunberg

គ្រួសារ : Alydidae

ការពិពណ៌នា :

ស្រឹងញីមានពោះធំកំប៉ោង រីឯស្រឹងឈ្មោលមានពោះតូច។ សត្វល្អិតចង្រៃនេះមានរាង២ប្រភេទគឺ: ប្រភេទខ្លួនវែង និងប្រភេទខ្លួនខ្លី។ ស្រឹងពេញវ័យមានពណ៌ត្នោត មានដងខ្លួនរាងស្រាវហើយមានជើង និងអង់តែនវែង។ នៅក្នុងលក្ខខណ្ឌចំណីអាហារមិនសមស្រប ពួកវាអាចលាក់ខ្លួនចិញ្ចឹមជីវិតនៅក្នុងគុម្ពស្មៅរយៈពេលពី២-៣ជំនាន់ មុនពេលវាធ្វើបម្លាស់ទីទៅរកស្រែផ្សេងនៅក្នុងដំណាក់កាលស្រូវចេញផ្កា។ ស្រឹងពេញវ័យមានពណ៌បៃតងប្រផេះ មានប្រវែង ១៤-១៧មម និងមានខ្លិនឆ្អួល។ ស្រឹងជញ្ជក់ទឹកដោះពងជាជួរៗ២-៣ជួរ មានចំនួនពងពី ១០-២០ពង

នៅលើស្លឹក និងកួរស្រូវដែលមានពណ៌ក្រហមក្រម៉ៅ និងមានរាងដូចផ្លែអង្គុញ វាអាចពងបាន ២០០-៣០០ពង ក្នុងជីវិតរយៈពេល៦៩ថ្ងៃរបស់វា។ ពងចំណាយពេល ៥-៩ថ្ងៃ ទើបញាស់ជាស្រឹងមានពណ៌បៃតងភ្លាវថ្លាដែលងាយច្រឡំនឹងស្លឹកស្រូវ និងលូតលាស់រយៈពេល ១៧-២៦ថ្ងៃទើបពេញវ័យ។



រូបភាព : វដ្តជីវិតរបស់ស្រឹងជញ្ជក់ទឹកដោះ
ប្រភព : អគ្គនាយកដ្ឋានកសិកម្ម


រូបភាព : ស្រឹងជញ្ជក់ទឹកដោះបំផ្លាញលើដំណាំស្រូវ
ប្រភព : M.A. Cobblah


រូបភាព : ស្រឹងជញ្ជក់ទឹកដោះពេញវ័យ
ប្រភព : IRRI

### ១.១.១០. ស្រឹងបៃតង

| | |
|---|---|
| **ឈ្មោះទូទៅជាភាសាខ្មែរ :** | ស្រឹងបៃតង |
| **ឈ្មោះទូទៅជាភាសាអង់គ្លេស :** | Green stink bug |
| **ឈ្មោះវិទ្យាសាស្ត្រ :** | *Nezara viridula* |
| **គ្រួសារ :** | Pentatomidae |

ការពិពណ៌នា :

ស្រឹង បៃតងមានរូបរាងខុសពីស្រឹងជញ្ជក់ទឹកដោះ ដោយខ្លួនរបស់វាខ្លីមានប្រវែងខ្លីជាង និងមានមាឌមាំជាង។ ស្រឹងបៃតង ប្រើប្រអប់មាត់ដ៏រឹងមាំរបស់វា ចោះចូលទៅក្នុងគ្រាប់ស្រូវ ដើម្បីជញ្ជក់បឺតយកសារធាតុពីក្នុងគ្រាប់ស្រូវ។ ស្រឹងជញ្ជក់បៃតងស៊ីជញ្ជក់លើគ្រាប់របស់ដំណាំជាច្រើនប្រភេទ រួមទាំងពពួកសណ្តែកដែរ។ កូនញាស់របស់ស្រឹងបៃតងមានពណ៌ខ្មៅ និងមានចំណុចលឿង និងក្រហមជាច្រើននៅលាយឡំគ្នា។ ស្រឹង បៃតងពេញវ័យជានិច្ចជាកាលមានពណ៌បៃតង។ ពងរបស់ស្រឹងបៃតង មានរាងដូចស្នៃហើយតម្រៀបជាជួរជិតៗគ្នា នៅលើស្លឹករុក្ខជាតិ។





### ១.១.១១. ទ្រីប

**ឈ្មោះទូទៅជាភាសាខ្មែរ :** ទ្រីប

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Thrips

**ឈ្មោះវិទ្យាសាស្ត្រ :** *Stenchaetothrips biformis*

**គ្រួសារ :** Thripidae

ការពិពណ៌នា :

ទ្រីបជាសត្វល្អិតចង្រៃបំផ្លាញដំណាំស្រូវ ជាពិសេសស្រូវស្ថិតនៅក្នុងដំណាក់កាលសំណាប។ វាបំផ្លាញនៅលើថ្នាល និងស្រូវពង្រោះដែលមានភាពរាំងស្ងួត។ ស្រូវដែលស្ថិតនៅក្នុងដំណាក់កាលបែកគុម្ពរហូតដល់បែកគុម្ពពេញទំហឹងមានការបំផ្លាញខ្លះៗតែប៉ុណ្ណោះ។ សត្វល្អិតចង្រៃប្រភេទនេះមានវត្តមាននៅគ្រប់បរិស្ថានដំណាំស្រូវទាំងអស់។ នៅតំបន់ត្រូពិចវាមានយ៉ាងច្រើន ចាប់ពីខែកក្កដា ដល់ខែកញ្ញា និងពីខែមករា ដល់ខែមីនា។ នៅពេលមានអាកាសធាតុអំណោយផលវាចាប់ផ្តើមធ្វើដំណើរទៅសម្ងំនៅគុម្ពស្មៅក្នុងកំឡុងពេលរដូវត្រជាក់។ ទ្រីបមានដងខ្លួនឆ្មារស្តើង ពណ៌ត្នោតចាស់ហើយវែងមានបណ្តោយប្រវែងពី ១ ទៅ ២មម មានអង់តែនពី ៥ ទៅ ៨កង់។ ទ្រីបមានពីរប្រភេទគឺ: ប្រភេទមានស្លាប និងប្រភេទគ្មានស្លាប។ ទ្រីបមានវដ្តជីវិតសរុបចំនួន៤០ថ្ងៃ ដែលពងមានអាយុកាល ៣ថ្ងៃ កូនមានរយៈពេល ១៦ថ្ងៃ ដឹកឌឿមានរយៈពេល ៣ថ្ងៃ មេមានអាយុកាល ១៨ថ្ងៃ។



រូបភាព : សត្វទ្រីបបំផ្លាញលើដំណាំស្រូវ
ប្រភព : IRRI



រូបភាព : សត្វទ្រីបញាស់
ប្រភព : IRRI



រូបភាព : រោគសញ្ញាបំផ្លាញដោយសត្វទ្រីប
ប្រភព : IRRI

### ១.១.១២. កណ្តូប

**ឈ្មោះទូទៅជាភាសាខ្មែរ :** កណ្តូប

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Rice grass hoppers

**ឈ្មោះវិទ្យាសាស្ត្រ :** *Atractomorpha psittacina, Oxyahyla intricata, Oxya japonica* និង *Euscrytus concinnus*

**គ្រួសារ :** Acrididae

ការពិពណ៌នា :

កណ្តូប គឺជាសត្វល្អិតចង្រៃដែលយើងបានជួបប្រទះនៅព្រះរាជាណាចក្រកម្ពុជា រួមមានៈ *Atractomorpha psittacina, Oxyahyla intricata, Oxya japonica* និង *Euscrytus concinnus*។ *Atractomorpha psittacina* មានអង់តែនខ្លីជាងដងខ្លួនមានរូបរាងប្រហាក់ប្រហែលកណ្តូបបុកស្រូវ។ *Oxyahyla intricata* មានអង់តែនខ្លីជាងដងខ្លួន វាចូលចិត្តរស់នៅក្នុងស្មៅ។ *Oxya japonica* មានអង់តែនខ្លីជាងដងខ្លួនហើយមានពណ៌បៃតង និងឆ្នូតមួយពណ៌លឿងបៃតងចាប់ពីក្បាលអូសបន្លាយតាមខ្នង និងមានចំណុចខ្មៅនៅតាមចំហៀងខ្លួន។

*Euscrytus concinnus* ជា សត្វកណ្តូបដែលមានអង់តែនវែងជាងដងខ្លួនហើយមានប្រអប់ជើងចែកជាបីកង់សត្វកណ្តូបមេមួយក្បាលអាចពងបានចាប់ពី ១០០-៣០០ពង។ វាពងជាកញ្ចុំៗមានចាប់ពី ៣៥-១០០ពង មានពណ៌សលឿង ឬពណ៌សត្នោត អាស្រ័យទៅតាមប្រភេទនៃកណ្តូបនីមួយៗ។ វាពងនៅក្នុងស្មៅ ឬនៅតាមស្រទបស្លឹកស្រូវ ឬពងនៅក្នុងដី។ វដ្តជីវិតរបស់កណ្តូបមានរយៈពេលសរុប ៧ខែ ដែលពងមានអាយុ ១ខែ កូនញាស់មានអាយុ៣ខែនិងបណ្តូបពេញវ័យមានអាចរស់បានរហូតដល់៣ខែ។



កណ្តូបពេញវ័យ

### ១.១.១៣. មូសផ្លុង

**ឈ្មោះទូទៅជាភាសាខ្មែរ :** មូសផ្លុង

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Gallmidge

**ឈ្មោះវិទ្យាសាស្ត្រ :** *Orseolia oryzae*

**គ្រួសារ :** Cecidomyiidae

ការពិពណ៌នា :

មូសផ្លុង ជាសត្វល្អិតដែលមានរូបរាងតូចដូចមូសធម្មតាដែរ។ ខ្លួនរបស់មូសផ្លុងឈ្មោលពេញវ័យ មានពណ៌លឿងត្នោត និងមានមាឌតូចជាងមូសផ្លុងញី ដែលមានពោះពណ៌ក្រហម។ មូសផ្លុងស៊ីបំផ្លាញដល់បណ្តូលខាងក្នុង

ដែលធ្វើឱ្យដើមស្រូវមានសណ្ឋានជាបំពង់ដូចស្លឹកផ្លុង ដែលគេនិយមហៅថារមូរផ្លុង ។ មូសផ្លុងស៊ីបំផ្លាញដំណាំស្រូវចាប់តាំងពីនៅវគ្គសំណាប រហូតដល់ចុងបញ្ចប់ នៃវគ្គបែកគុម្ព ។ មូសផ្លុងចេញពីក្នុង ប្រហោងរមូរស្លឹកដូចស្លឹកផ្លុង ដោយបន្សល់ទុកសំបុកដឹកឡើនៅជាប់ ចុងស្លឹកដែលវាបំផ្លាញនោះ។



រូបភាព : មូសផ្លុងពេញវ័យ
ប្រភព : IRRI



រូបភាព : ដើមស្រូវដែលរងការបំផ្លាញដោយមូសផ្លុង
ប្រភព : Merle Shepard

### ១.១.១៤. ដង្កូវស្នែង

| | |
|---|---|
| **ឈ្មោះទូទៅជាភាសាខ្មែរ** | ដង្កូវស្នែង |
| **ឈ្មោះទូទៅជាភាសាអង់គ្លេស :** | Rice butterfly |
| **ឈ្មោះវិទ្យាសាស្ត្រ :** | *Melanitis leda* ismene |
| **គ្រួសារ :** | Nymphalidae |

ការពិពណ៌នា :

នៅលើដំណាំស្រូវមានដង្កូវស្នែងពីឬប្រភេទសំខាន់ៗ គឺ Melanitis និង Mycalesis ដែលមានលក្ខណៈខុសគ្នាដោយគំនូរមានសណ្ឋាននៅលើស្លាប និងក្រោមស្លាបរបស់វា។ មេអំបៅដង្កូវស្នែង Melanitis មានចំណុចរាងជាចំណុចវង់ពណ៌សពីរ នៅលើស្លាបខាងមុខ និងមានចំណុចរង្វង់ប្រាំពីរ នៅផ្នែកចុងនៃស្លាបខាងក្រោយ។ នៅផ្នែកផ្ទៃខាងក្រោមនៃស្លាប មានចំណុចវង់បីនៅស្លាបខាងមុខ និងប្រាំមួយនៅលើស្លាបខាងក្រោយ។ ពងមានពណ៌ភ្លឺរលោង និងមានរាងដូចស្វៃរ។ ដង្កូវស៊ីកាត់ ផ្តាច់គែមស្លឹក និងចុងស្លឹកស្រូវ។



រូបភាព : ដឹកឡើ
ប្រភព : Clive Lau



រូបភាព : ដង្កូវស្នែង
ប្រភព : Clive Lau



រូបភាព : ដង្កូវស្នែងចតជិត
ប្រភព : Ernst Neering

### ១.១.១៥. ដង្កូវភ្នែកឆ្មារ

ឈ្មោះទូទៅជាភាសាខ្មែរ : ដង្កូវភ្នែកឆ្មារ
ឈ្មោះទូទៅជាភាសាអង់គ្លេស : Rice skipper
ឈ្មោះវិទ្យាសាស្ត្រ : *Parnara guttata*
គ្រួសារ : Hesperiidae

ការពិពណ៌នា :

មេអំបៅដង្កូវភ្នែកឆ្មារហើរត្រាច់ចរនៅពេលថ្ងៃ ហើយជារឿយៗវាជំញក់បឺតយកទឹកដមពីផ្កា។ ពងរបស់វាមានរាងដូចគុជរាយមួយៗនៅលើផ្ទៃស្លឹក។ ដង្កូវរបស់មេអំបៅនេះមានទំហំខ្លួនប៉ុនគ្នានឹងដង្កូវស្នែងដែរ ប៉ុន្តែវាគ្មានស្នែងទេ។ ក្បាលដង្កូវមានរាងសំប៉ែត ហើយទេរទៅក្រោយបន្តិច។ ស្លឹកស្រូវដែលបំផ្លាញដោយដង្កូវនេះ មានលក្ខណៈស្រដៀងគ្នាទៅនឹងការបំផ្លាញរបស់ដង្កូវស្នែងដែរ។ ដង្កូវភ្នែកឆ្មារធ្វើជម្រកនៅក្នុងស្លឹកបត់ ប៉ុន្តែវិធីនៅក្នុងការបត់ស្លឹកធ្វើជម្រកខុសពីដង្កូវមូរស្លឹក។ ដង្កូវភ្នែកឆ្មារទាញចុងស្លឹកបត់មកភ្ជាប់បត់មកភ្ជាប់ផ្នែកខាងក្រោមបង្កើតជាសំបុកការពារ។


រូបភាព : ពងរបស់ដង្កូវភ្នែកឆ្មារ
ប្រភព : James Litsinger


រូបភាព : ដង្កូវភ្នែកឆ្មាទើបញាស់
ប្រភព : James Litsinger


រូបភាព : លក្ខណៈសំបុករបស់ដង្កូវភ្នែកឆ្មា
ប្រភព : James Litsinger


រូបភាព : មេអំបៅរបស់ដង្កូវភ្នែកឆ្មារ
ប្រភព : James Litsinger


រូបភាព : មេអំបៅរបស់ដង្កូវភ្នែកឆ្មារទាំង២ប្រភេទ
ប្រភព : James Litsinger

### ១.១.១៦. ខ្មុងបន្លា

**ឈ្មោះទូទៅជាភាសាខ្មែរ :** ខ្មុងបន្លា

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Rice hispa

**ឈ្មោះវិទ្យាសាស្ត្រ :** *Dicladispa armigera*

**គ្រួសារ :** Cecidomyiidae

ការពិពណ៌នា :

សត្វល្អិតនេះរស់នៅក្នុងវាលស្មៅក្បែរ និងនៅក្នុងស្រែ។ វាប្រើប្រាស់វាលស្មៅដើម្បីធ្វើជារុក្ខជាតិជម្រក និងធ្វើការវិវត្តខ្លួនរបស់វា។ ការប្រើប្រាស់ជីអាសូតលើសកម្រិតណែនាំ គឺជាកត្តាចម្រុញការលូតលាស់យ៉ាងឆាប់រហ័ស។ ខ្មុងបន្លារបំផ្លាញដំណាំស្រូវយ៉ាងខ្លាំង ជាពិសេសប្រព័ន្ធដំណាំស្រូវពឹងផ្អែកទឹកភ្លៀង។ ខ្មុងបន្លាបំផ្លាញនៅលើដំណាំស្រូវ ធ្វើឱ្យស្រូវផ្អែកខាងចុងរួញ វាជញ្ជក់យកជាលិកានៅលើផ្ទៃស្លឹកស្រូវ ធ្វើឱ្យស្រូវមានស្នាមឆ្នូតពណ៌ស នៅតាមបណ្តោយស្លឹក។ ការបំផ្លាញខ្លាំងអាចធ្វើឱ្យទិន្នផលស្រូវបាត់បង់ប្រមាណ២០%។




### ១.១.១៧. ចៃម្សៅលើស្រូវ

**ឈ្មោះទូទៅជាភាសាខ្មែរ :** ចៃម្សៅលើស្រូវ

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Rice mealybug

**ឈ្មោះវិទ្យាសាស្ត្រ :** *Brevennia rehi*

**គ្រួសារ :** Pseudococcidae

ការពិពណ៌នា :

ទាំងកូនទើបញាស់ និងមេពេញវ័យបំផ្លាញដំណាំស្រូវដោយធ្វើការចុចជញ្ជក់យករុក្ខរស ពីដើមស្រូវ ហើយធ្វើឱ្យដើមមានរួញ ប្រែទៅជាពណ៌លឿង និងស្រពោន។ នៅរដូវប្រាំងចៃសលាក់ខ្លួននៅក្នុងគុម្ពស្មៅជុំវិញស្រែ ហើយធ្វើការបន្តពូជនៅទីនោះ។ ដីដែល បានរៀបចំរួច ក៏អាចជាជម្រកដ៏ប្រសើរសម្រាប់ចៃសនេះដែរ។ វាធ្វើការបំផ្លាញដំណាំស្រូវខ្លាំងនៅដំណាកាលស្រូវបែកគុម្ព ជាពិសេសក្នុងកំឡុងពេលជួបប្រទះគ្រោះរាំងស្ងួត។ កូនទើបញាស់ជញ្ជក់ស្រូវ តាំងពីញាស់ភ្លាមៗ រហូតដល់ដំណាក់កាលក្លាយជាដឹកឡើ។ វាធ្វើការបន្តពូជចាប់ពីខែមេសា ដល់ខែកក្កដា ក្នុងរយៈពេលនេះវាអាចធ្វើការបន្តពូជបាន២ដង។





១.១.១៨. ដង្កូវរុយ

ឈ្មោះទូទៅជាភាសាខ្មែរ : ដង្កូវរុយ

ឈ្មោះទូទៅជាភាសាអង់គ្លេស : Whorl maggot

ឈ្មោះវិទ្យាសាស្ត្រ : *Hydrellia philippina* Ferino

គ្រួសារ : Ephydridae

ការពិពណ៌នា :

ស្រូវដែលបំផ្លាញដោយដង្កូវរុយមានស្នាមអុចពណ៌លឿង និងមានប្រហោងធ្លុះពណ៌ស។ ដង្កូវរបស់វាមានក្រអូមមាត់រឹង ដែលអាចចោះទម្លុះជាលិកាស្លឹកស្រូវ។ ដង្កូវនេះធ្វើការបំផ្លាញស្លឹកស្រូវខ្ចីៗដែលទើបលាស់ត្រួយ ហើយស្នាមបំផ្លាញនេះមើលឃើញនៅពេលដែលស្លឹកចាស់។ ដំណាំស្រូវនៅដំណាក់កាលបែកគុម្ពអស់រងការបំផ្លាញខ្លាំងពីពពួកដង្កូវរុយនេះ។







### ១.១.១៩. ចៃឫសស្រូវ

**ឈ្មោះទូទៅជាភាសាខ្មែរ :** ចៃឫសស្រូវ

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Root aphid

**ឈ្មោះវិទ្យាសាស្ត្រ :** *Tetraneura nigriabdominalis* Sasaki

**គ្រួសារ :** Aphididae

ការពិពណ៌នា :

កូនទើបញាស់ និងមេពេញវ័យធ្វើការបំផ្លាញដោយជញ្ជក់យករុក្ខរសពីដើមស្រូវ ធ្វើឱ្យដើមស្រូវប្រែទៅជាពណ៌លឿង និងរួញ។ ការបំផ្លាញមានលក្ខណៈជាដុំៗនៅក្នុងស្រែ។ អាកាសធាតុក្តៅ និងរាំងស្ងួតរយៈពេលខ្លីគឺជាកត្តាអំណោយផលដល់ការលូតលាស់របស់ចៃនៅដំណាក់កាលនេះចៃអាចធ្វើការបន្តពូជបានយ៉ាងឆាប់រហ័ស។ វាមិនមានវត្តមាននៅលើដំណាំស្រូវដែលពឹងផ្អែកលើប្រព័ន្ធស្រោចស្រពទេ។ ចៃពេញវ័យរស់នៅក្នុងដី លើឫសរបស់ស្រូវ។ ពួកវាអាចរស់នៅក្នុងប្រហោងជុំវិញប្រព័ន្ធឫសដែលធ្វើឡើងពីសត្វស្រមោចផងដែរ។ កូនចៃពណ៌ត្នោតបញ្ចេញទឹកមានជាតិស្ករពីក្នុងខ្លួន ដែលអាចទាក់ទាញពួកស្រមោច។






### ១.១.២០. ស្រមោចភ្លើង

**ឈ្មោះទូទៅជាភាសាខ្មែរ :** ស្រមោចភ្លើង

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Tropical fire ant

**ឈ្មោះវិទ្យាសាស្ត្រ :** *Solenopsis geminata* Fabricius

**គ្រួសារ :** Formicidae

ការពិពណ៌នា :

ស្រមោចភ្លើងចូលចិត្តរស់នៅតាមភ្លឺស្រែតំបន់ទំនាប ឬតំបន់ខ្ពស់។ ពួកវាមិនចូលចិត្តរស់នៅតំបន់ដីស្រែលិចទឹកទេ។ ស្រមោចមានច្រើនប្រភេទដូចជាស្រមោចភ្លើងដែលជួនកាលវាស៊ីបំផ្លាញគ្រាប់ស្រូវ ដែលទើបនឹងសាបនិងស៊ីបំផ្លាញស្លឹក។ ជាពិសេសទៅទៀត ស្រមោចនេះវាចូលចិត្តស្វែងរកចាប់សត្វល្អិតដ៏ទៃទៀតជាចំណីអាហារផងដែរ។ ស្រមោចនេះស្វែងរកចំណីដូចជា គ្រាប់ស្រូវដែលសាបនៅពេលយប់ក្នុងស្រែគ្មានទឹក។ ពួកវាពាំជញ្ជូនគ្រាប់ស្រូវទាំងនោះទៅទុកនៅក្នុងសំបុកក្រោមដី ជាហេតុបណ្តាលឱ្យស្រូវក្នុងស្រែមានការបាត់គុម្ព។ ការសាបគ្រាប់ស្រូវទុកយូរនៅក្នុងស្រែគ្មានទឹក ធ្វើឱ្យមានការបាត់បង់កាន់តែច្រើន ហេតុដូច្នេះហើយភ្លៀងជាកត្តាសំខាន់នៅពេលសាបព្រោះ ក្នុងស្រែដែលមានវត្តមានសត្វស្រមោចភ្លើងនេះ។





១.១.២១. ខ្មុលដី

| | |
|---|---|
| ឈ្មោះទូទៅជាភាសាខ្មែរ : | ខ្មុលដី |
| ឈ្មោះទូទៅជាភាសាអង់គ្លេស : | Mole cricket |
| ឈ្មោះវិទ្យាសាស្ត្រ : | *Gryllotalpa orientalis* Burmeister |
| គ្រួសារ : | Gryllotalpidae |

ការពិពណ៌នា:

គេអាចសំគាល់វាបានដោយទំហំខ្លួនវាធំ ទ្រូង និងជើងខាងមុខមានមាឌធំ។ ខ្មុលដី គឺជាសត្វល្អិតដែលរស់នៅក្នុងដី និងជាសត្វល្អិតដែលពូកែហើរ ទោះបីជាមានស្លាបខ្លីក៏ដោយ ម្យ៉ាងទៀតវាជាសត្វល្អិតចង្រៃចូលចិត្តពន្លឺភ្លើង។ សត្វពេញវ័យ និងកូនរបស់វាស៊ីបំផ្លាញប្រព័ន្ធឬស។ ខ្មុលដីជីករូងចូលទៅក្នុងដីដោយសារជើងធំខាងមុខរបស់វា។ សត្វពេញវ័យអាចស៊ីគ្រាប់ស្រូវដែលសាបព្រោះ និងប្រព័ន្ធឬស។ ពួកវាក៏អាចស្វែងរកចំណីដូចគ្រាប់ស្រូវ ឬសត្វល្អិតដ៏ទៃទៀតនៅលើដីផងដែរ។ នៅពេលថ្ងៃវាលាក់ខ្លួននៅក្រោមដី ហើយជារឿយៗគេអាចប្រទះឃើញវាហែលទឹកនៅក្នុងស្រែលិចទឹក។ ប្រជាករវាអាចកើនឡើងខ្ពស់ខុសពីធម្មតា បើសិនរដូវប្រាំងមានរយៈពេលខ្លី។ ស្រូវដែលនៅតូច ឬដំណាក់កាលបែកគុម្ពដំបូង អាចងាប់ដោយសារការបាត់បង់ឬសដោយបង្កើតជាស្នាមវាលបាត់គុម្ពជុំៗនៅក្នុងស្រែ។



## ១.១.២២. ម៉ែក្ទរស្រូវ

ឈ្មោះទូទៅជាភាសាខ្មែរ : ម៉ែក្ទរស្រូវ

ឈ្មោះទូទៅជាភាសាអង់គ្លេស : Panicle rice mite

ឈ្មោះវិទ្យាសាស្ត្រ : *Steneotarsonemus spinki*

គ្រួសារ : Tarsonemidae

ការពិពណ៌នា :



រូបភាព : ការបំផ្លាញដោយការបំផ្លាញម៉ែស្រូវ

ប្រភព : Natalie Hummel, Louisiana State University AgCenter, Bugwood.org, CC BY-NC)



រូបភាព : រោគសញ្ញាដោយការបំផ្លាញម៉ែស្រូវ

ប្រភព : Lalnunpuii Parte, Krishi Vigyan Kendra, Bugwood.org, CC BY-NC

ម៉ែក្ទរស្រូវ ជញ្ជក់បំផ្លាញនៅលើស្រូវពីដំណាក់កាលសំណាបដល់ដំណាក់កាលចេញកក្ទរ។ ម៉ែក្ទរស្រូវ បំផ្លាញគ្រាប់ស្រូវ ស្លឹកសរសៃវ៉ែន និងស្រទបស្លឹក (ហើយវាក៏ត្រូវបានគេស្គាល់ថាជាម៉ែស្រទបស្លឹកស្រូវ)។ ការបំផ្លាញរបស់វានៅស្រទបស្លឹកខាងក្រោយ ហើយការបំផ្លាញជាលិកាអាចត្រូវបានរកឃើញដោយការប្រែពណ៌ទៅជាពណ៌ស្វាយ-ត្នោតនៃស្រទបស្លឹក។ នៅពេលដែលស្លឹកចាប់ផ្ដើមលូតលាស់ ម៉ែញីនឹងផ្លាស់ទីទៅស្រទបស្លឹកខ្ចីៗ និងបង្កើតកូនចៅ បន្ទាប់មកបំផ្លាញនៅជាលិកាថ្មីៗ ហើយលក្ខខណ្ឌអាកាសធាតុក្ដៅហើយស្ងួតជាលក្ខខណ្ឌសមស្របសម្រាប់ការលូតលាស់របស់ម៉ែក្ទរស្រូវ។

ម៉ែពេញវ័យមានខ្លួនតូចៗប្រវែងពី ០.២-១ម.ម និងមានពណ៌ត្នោតថ្លា ហើយមានជើងចំនួន ៨។ សត្វឈ្មោលមានប្រវែងខ្លីជាងសត្វញី ហើយសត្វញីអាចពងបាន ៥០ពង នៅស្រទបស្លឹក។ វដ្តជីវិតពេញលេញមានរយៈពេលពី ១០-១៣ថ្ងៃ (ពង ១-២ថ្ងៃ, កូន៤-៥ថ្ងៃ, សត្វពេញវ័យ ៥-៦ថ្ងៃ)។

## ១.២ សត្វចង្រៃលើដំណាំស្រូវ

### ១.២.១. កណ្ដុរ

ឈ្មោះទូទៅជាភាសាខ្មែរ : កណ្ដុរ

ឈ្មោះទូទៅជាភាសាអង់គ្លេស : Rat

ឈ្មោះវិទ្យាសាស្ត្រ : *Bandicota indica* និង *Rattus argentiventer*

គ្រួសារ : Muridae

ការពិពណ៌នា :

សត្វកណ្ដុរដែលប្រទះឃើញសំបូរជាងគេនៅក្នុងស្រែកសិករក្នុងតំបន់វាលទំនាបនៃប្រទេសកម្ពុជារួមមានពួកកណ្ដុរប្រេង ឬកណ្ដុរធំ (*Bandicota indica*) និងពួកកណ្ដុរស្រែ ឬកណ្ដុរបាយ (*Rattus argentiventer*)។ កណ្ដុរជាសត្វដែលមានភ្នែកមិនសូវពូកែ (មើលពុំសូវច្បាស់) និងជាសត្វដែលរពឹស តែមានភាពវៃឆ្លាតក្នុងការស្រង់ក្លិន។ កណ្ដុរមានពុកមាត់ និងរោមព្រែងសំរាប់នាំផ្លូវនៅពេលដែលវាផ្លាស់ប្ដូរជម្រករបស់វា។ ធ្មេញមុខរបស់កណ្ដុរមានរាងដូចពន្លាកហើយធ្មុំដូចជាកន្ត្រៃ។ វាពូកែឡើងដើមឈើ និងពូកែហែលទឹក។ កណ្ដុរជាសត្វដែលចូលចិត្តរស់នៅជាហ្វូង។

- កណ្ដុរស្រែអាចរស់បានជាមធ្យមពី ៦ខែ ទៅជាង ១ឆ្នាំ
- កណ្ដុរពេញវ័យនៅអាយុ ៣ខែ អាចធ្វើការបន្តពូជបាន
- កណ្ដុរឈ្មោល២-៣ក្បាលអាចបង្កាត់ពូជជាមួយកណ្ដុរញីរាប់រយក្នុងតំបន់តែមួយ
- កណ្ដុរកើតកូនភ្លាមអាចបន្តការបន្តពូជទៀតបាន
- កណ្ដុរធើមរយៈពេល២១ថ្ងៃ គិតចាប់ពីថ្ងៃវាបន្តពូជជាមួយកណ្ដុរឈ្មោល
- កណ្ដុរឈ្មោល១ក្បាល និងកណ្ដុរញី១ក្បាលអាចបង្កើតកូនបាន ៣-៤ដងក្នុង១ឆ្នាំ(៣ខែកូនម្ដង)
- កូនម្ដងជាមធ្យមចំនួន ៦ក្បាល គឺឈ្មោល ៣ក្បាល និងញី ៣ក្បាល
- ក្នុងរយៈពេល ១ឆ្នាំ កណ្ដុរឈ្មោល១ក្បាល និងកណ្ដុរញី១ក្បាល អាចពង្រីកកូនចៅ បានរហូតដល់ចំនួន ២០៤៦
  ក្បាល។




រូបភាព : វដ្ដជីវិតរបស់កណ្ដុរ
ប្រភព : អគ្គនាយកដ្ឋានកសិកម្ម



រូបភាព : កណ្ដុរស្រែ ឬកណ្ដុរបាយ
ប្រភព : Ho Cheng Tuck/Tropical Press Sdn Bhd



រូបភាព : កណ្ដុរប្រេង ឬកណ្ដុរធំ
ប្រភព : IRRI

### ១.២.២. ខ្យងមាស

**ឈ្មោះទូទៅជាភាសាខ្មែរ :** ខ្យងមាស

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Golden apple snail

**ឈ្មោះវិទ្យាសាស្ត្រ :** *Pomacea canaliculata* និង *Pomacea maculate*

**គ្រួសារ :** Ampullariidae

ការពិពណ៌នា :

ខ្យងមាសមានរូបរាងដូចគ្នានឹងខ្យងស្រុកដែរ តែខុសគ្នាត្រង់វាមានពណ៌មាស។ វាអាចរស់នៅបានយ៉ាងយូរហូតដល់ ២-៦ឆ្នាំ។ ស្នូករបស់វាមានពណ៌ត្នោតចាស់ សាច់មានខ្លាញ់ពណ៌ស និងមានពណ៌ផ្កាឈូកលាយពណ៌មាស ឬពណ៌ទឹកក្រូចលាយពណ៌មាស។ ទំហំរបស់ខ្យងមាសធំ ឬតូចអាស្រ័យលើការរកចំណីស៊ីបានច្រើនឬតិច។ ដំណាក់កាលបំផ្លាញខ្លាំងគឺនៅពេលដែលបណ្ដោយនៃសំបកមានប្រវែងចន្លោះពី ១០មម (ទំហំប៉ុនគ្រាប់ពោត) ទៅ ៤០មម(ទំហំប៉ុនគ្រាប់ប៉េងប៉ុង)។ សន្ទះគំរបមាត់ខ្យងមាសញីមានសណ្ឋានផត ពណ៌សផ្ទុយពីសត្វឈ្មោលដែលប៉ោង។ ខ្យងមាសញីពេញវ័យសន្ទះគំរបមាត់របស់វាកោងចូលក្នុងខ្លួន រីឯឈ្មោលវិញកោងចេញមកក្រៅខ្លួន។ សត្វខ្យងមាសអាចរស់នៅបានដូចជានៅក្នុងស្រះ វាល ល្បាប់ ភក់ ស្រែបញ្ចូលទឹក ប្រឡាយ និង កន្លែងដែលមានទឹកដក់។ ពពួកសត្វខ្យងមាសនេះកប់ខ្លួនក្នុងដីសើម (រស់នៅជាជីវិតក្រាំង) នៅក្នុងរដូវប្រាំង។ ក្នុងរដូវក្ដៅវាអាចក្រាំងបានយូរហូតដល់៦ខែហើយវាត្រឡប់មករស់រើកម្ដងទៀតនៅពេលត្រូវលិចទឹក។ វាក៏អាចរស់បាននៅក្នុងលក្ខខណ្ឌបរិស្ថានអាក្រក់ដូចជាភាពកខ្វក់នៅក្នុងទឹក ឬកម្រិតអុកស៊ីសែនទាប។ ខ្យងមាសស៊ីអាហារដូចជាសារ៉ាយ ស្លែ ចក កំប្លោក សំណាប និងស្លឹករុក្ខជាតិមានឱជារសដទៃទៀត។ វាចូលចិត្តស៊ីផ្នែកខ្ចីៗនៃរុក្ខជាតិដែលទន់ៗ (មិនគ្រើម ឬរឹង) ព្រោះវាស៊ីចំណីដោយកោសផ្ទៃរុក្ខជាតិជាមួយនឹងអណ្ដាតគគ្រាតរបស់វា និងស៊ីផងដែរនូវចំណីរលួយដែលបានមកពីការបំបែករូបធាតុសរីរាង្គនានា។



រូបភាព : ពងខ្យងទើបទម្លាក់រួច

ប្រភព : IRRI



រូបភាព : ខ្យងមាសពេញវ័យ

ប្រភព : IRRI

## ១.៣. ជំងឺបង្កឡើងដោយផ្សិត

### ១.៣.១ ជំងឺប្លាស់

| | |
|---|---|
| ឈ្មោះទូទៅជាភាសាខ្មែរ : | ជំងឺប្លាស់ |
| ឈ្មោះទូទៅជាភាសាអង់គ្លេស : | Rice blast |
| ឈ្មោះវិទ្យាសាស្ត្រ : | *Pyricularia oryzae* |
| គ្រួសារ : | Magnaporthaceae |

ការពិពណ៌នា :




នៅលើស្លឹកមានស្នាមអុចជាំពណ៌ត្នោតក្រម៉ៅរាងពងក្រពើ ឬទ្រវែងស្រួចសងខាង និងនៅចំកណ្តាលចំណុចមានពណ៌ប្រផេះភ្លឺ។ ដំបូងស្នាមអុចមានទំហំតូច បន្ទាប់មករីករាលដាលយ៉ាងឆាប់រហ័ស និងករណីធ្ងន់ធ្ងររហូតដល់ពាសពេញផ្ទៃស្លឹក។ នៅលើទង (ចង្កំស្លឹក) មានស្នាមពណ៌ត្នោតត្រង់ចំណុចភ្ជាប់គ្នារវាងស្លឹក និងស្រទបស្លឹក ដែលអាចធ្វើអោយស្លឹកស្រូវទាំងមូលងាប់។ រីឯលើថ្នាំងរបស់ដើមវិញ ស្នាមត្នោតខ្មៅរាលដាលលើថ្នាំងទាំងមូលដែលអាចធ្វើអោយដើមបាក់។ លើក្ឃួរស្រូវវិញករបស់ក្ឃួរស្រូវមានពណ៌ខ្មៅរាងប្រផេះ ធ្វើអោយក្ឃួរទាំងមូលស្កកមិនដាក់គ្រាប់ពេញលេញ និងគ្រាប់ស្រូវមានស្នាមពណ៌ត្នោតទ្រវែង។



រូបភាព : រោគសញ្ញាប្លាស់លើស្លឹក
ប្រភព : Chin Khoon Min



រូបភាព : រោគសញ្ញាប្លាស់លើក្ឃួរ
ប្រភព : Chin Khoon Min



រូបភាព : រោគសញ្ញាប្លាស់លើក្ឃួរ
ប្រភព : Chin Khoon Min





រូបភាព : រោគសញ្ញាបំផ្លាញលើថ្នាំង និងស្រែដែលរងការបំផ្លាញ
ប្រភព : Chin Khoon Min

### ១.៣.២ ជំងឺអុចត្នោត

**ឈ្មោះទូទៅជាភាសាខ្មែរ :** ជំងឺអុចត្នោត

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Brown Spot

**ឈ្មោះវិទ្យាសាស្ត្រ :** *Helmithosporium oryzae* ឬ *Cochliobolus miyabeanus*

**គ្រួសារ :** Pleosporaceae

ការពិពណ៌នា :

ជំងឺនេះកើតឡើងនៅគ្រប់ដំណាក់កាលលូតលាស់ និងគ្រប់ផ្នែកទាំងអស់នៃដំណាំស្រូវ។ រោគសញ្ញានៃជំងឺនេះត្រូវបានមើលឃើញយ៉ាងច្បាស់នៅលើស្លឹកស្រូវ ហើយរោគសញ្ញាទូទៅរបស់វាគឺមានពណ៌ត្នោតអុចៗលើស្លឹក។ នៅពេលដែលយើងប្រើប្រាស់ពូជដែលមានជំងឺ វាអាចបណ្តាលឲ្យកើតជំងឺនៅលើថ្នាលសំណាប។ ដំណាក់កាលដែលចេញរោគសញ្ញាជំងឺអុចត្នោតច្រើនបំផុត គឺនៅដំណាំកាលស្រូវបែកគុម្ព ហើយផុតពីនេះ គឺចេញរោគសញ្ញានៅលើករកួរស្រូវ ដែលមានរោគសញ្ញាអុចខ្មៅនៅលើថ្នាំង។ កូនសំណាបនៅតូចមានរោគសញ្ញារលាកលើស្រទបស្លឹក ដែលធ្វើអោយក្រិន ឬងាប់។ នៅលើស្លឹកមានស្នាមអុចជាំពណ៌ត្នោតក្រម៉ៅរាងមូល និងនៅចំកណ្តាលមានចំណុចពណ៌ប្រផេះភ្លឺ។ នៅលើកួរស្រូវ និងគ្រាប់ស្រូវមានស្នាមអុចពណ៌ត្នោត ។ រីឯលើឫសខ្ចីវិញមានដំបៅពណ៌ខ្មៅ។





រូបភាព : ស្នាមអុចនៅលើស្លឹក និងគ្រាប់ បង្កឡើងដោយជំងឺអុចត្នោត

ប្រភព : IRRI

# ផ្នែកទី២
# ដំណាំបន្លែយកផ្លែ

### ១.៣.៣ ជំងឺរលួយស្រទបស្លឹក

**ឈ្មោះទូទៅជាភាសាខ្មែរ :** ជំងឺរលួយស្រទបស្លឹក

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Sheath rot

**ឈ្មោះវិទ្យាសាស្ត្រ :** *Sarocladium oryzae*

**គ្រួសារ :** Hypocreomycetidae

ការពិពណ៌នា :

រោគសញ្ញានៃជំងឺនេះ យើងសង្កេតឃើញស្នាមរលួយនៅលើស្រទបស្លឹក និងធ្វើឱ្យកួរស្រូវមិនអាចលូតលាស់ចេញផ្កាតាមធម្មតាបាន។ ជាដំបូងមានចំណុចរលួយដែលមានគែមពណ៌ត្នោតស្រាលនិងផ្ទៃកកណ្ដាលពណ៌ប្រផេះ។ បន្ទាប់មកស្នាមទាំងនោះនឹងរីករាលដាលធំឡើងៗ ពាសពេញស្រទបស្លឹក។ ក្នុងករណីធ្ងន់ធ្ងរកួរស្រូវទាំងមូលមិនអាចលេចចេញពីស្រទបស្លឹក និងប្រែពណ៌ទៅជាពណ៌ត្នោតមិនអាចដាក់គ្រាប់បានពេញលេញ។ ជាធម្មតាផ្សិត *Sarocladium oryzae* អាចបង្កជំងឺបានអាស្រ័យដោយស្រទបស្លឹកមានស្នាមរបួសពីការបំផ្លាញរបស់សត្វល្អិតដទៃទៀតលើស្រទបស្លឹកទង់ជ័យ។



រូបភាព : ស្នាមរលាកនៅលើស្លឹកទង់ជ័យបង្កឡើងដោយជំងឺស្រទបស្លឹក
ប្រភព : Chin Khoon Min

### ១.៣.៤ ជំងឺរលួយដើម

**ឈ្មោះទូទៅជាភាសាខ្មែរ :** ជំងឺរលួយដើម

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Stem rot

**ឈ្មោះវិទ្យាសាស្ត្រ :** *Sclerotium oryzae* Cattaneo

**គ្រួសារ :** Typhulaceae

ការពិពណ៌នា :

ជាទូទៅជំងឺនេះយើងសង្កេតឃើញកើតឡើងនៅពាក់កណ្ដាលដំណាក់កាលស្រូវបែកគុម្ព។ ដើមស្រូវ និងស្រទបស្លឹករលួយ បន្ទាប់មកធ្វើឱ្យដើមស្រូវទាំងមូលដួលរលំទៅលើដី នៅពេលស្រូវចាប់ផ្ដើមដាក់គ្រាប់។ ការរីករាលដាលនៃជំងឺនេះ ជាទូទៅកើតឡើងនៅពេលស្រូវមានអាយុកាល ១-១.៥ខែ ក្រោយពេលស្ទូងរហូតដល់ស្រូវផើម។ ការរលួយនេះស្ថិតនៅផ្ទៃកខាងក្នុងនៃដើមស្រូវ មានពណ៌ជាំខ្មៅ នៅជុំវិញដើមស្រូវ។



រូបភាព: រោគសញ្ញាបង្កឡើងដោយជំងឺរលួយដើម
ប្រភព: IRRI



រូបភាព: ស្គ្លែររបស់ផ្សិត *Sclerotium oryzae Cattaneo*
ប្រភព: Chin Khoon Min

### ១.៣.៥ ជំងឺធ្យូងបៃតង

**ឈ្មោះទូទៅជាភាសាខ្មែរ:** ជំងឺធ្យូងបៃតង
**ឈ្មោះទូទៅជាភាសាអង់គ្លេស:** False smut
**ឈ្មោះវិទ្យាសាស្ត្រ:** *Ustilaginodea virens* Cooke
**គ្រួសារ:** Ustilaginoidea

ការពិពណ៌នា:

ជំងឺនេះ កើតឡើងនៅដំណាក់កាលកំណកំណើតកួរ របស់ស្រូវ។ គេសង្កេតឃើញនៅលើកួរស្រូវ មានគ្រាប់ស្រូវខ្លះ មានដុំពណ៌លឿង ទុំ ដុះជាកញ្ចុំដូចដុំធូលីព័ទ្ធជុំវិញគ្រាប់ស្រូវ ហើយក្រោយមកវិវត្តន៍ទៅជាដុំបៃតង ខ្មៅ។ ជំងឺនេះបង្កដោយផ្សិត*Ustilaginodea virens* Cooke ដែលមានទំហំស្ព័រ ៣-៥ មីក្រូម៉ែត្រ X ៤-៦ មីក្រូម៉ែត្រ រាលដាលខ្លាំងនៅពេលស្រូវចាប់ចេញផ្កា និងមានអាកាសធាតុសើម ។ ម្យ៉ាងទៀតបណ្តាលមកពីការដាក់ជីអាសូតលើសកម្រិត។



រូបភាព: រោគសញ្ញាបង្កឡើងដោយជំងឺធ្យូងបៃតងដំណាក់កាលដំបូង
ប្រភព: IRRI



រូបភាព: រោគសញ្ញាបង្កឡើងដោយជំងឺធ្យូងបៃតងដំណាក់កាលធ្ងន់ធ្ងរ
ប្រភព: IRRI

### ១.៣.៦ ជំងឺស្រូវឈ្មោល

**ឈ្មោះទូទៅជាភាសាខ្មែរ :** ជំងឺស្រូវឈ្មោល

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** *Bakanae*

**ឈ្មោះវិទ្យាសាស្ត្រ :** *Gibberella fujikuroi*

**គ្រួសារ :** *Nectriaceae*

ការពិពណ៌នា :

ជំងឺនេះជាជំងឺមួយដែលបំផ្លាញខ្លាំងលើដំណាំស្រូវ ហើយធ្វើឱ្យស្រូវមានការលូតកំពស់ខុសប្រក្រតី។ ម្យ៉ាងទៀតដើមស្រូវដែលកើតជំងឺនេះត្រូវបានងាប់ មុនពេលចាប់ផ្តើមកំណកំណើតកួរ ឬបើពុំដូច្នោះទេដើមស្រូវទាំងនោះពុំមាននិប្ផលភាព ឬអារគ្មានកួរ។ ពន្លករុក្ខជាតិមានពណ៌លឿង រួញ ស្ងួតឬស រលួយ ហើយដើមស្រូវលូតវែងខុសធម្មតា។



រូបភាព : ដើមលូតខ្ពស់ខុសប្រក្រតីបង្កឡើងដោយជំងឺស្រូវឈ្មោល

ប្រភព : IRRI

### ១.៣.៧ ជំងឺរលាកស្រទបស្លឹក

**ឈ្មោះទូទៅជាភាសាខ្មែរ :** ជំងឺរលាកស្រទបស្លឹក

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Sheath blight

**ឈ្មោះវិទ្យាសាស្ត្រ :** *Rhizoctonia solani*

**គ្រួសារ :** Ceratobasidiaceae

ការពិពណ៌នា :

ស្នាមរលាកនៅលើដើមស្រូវក្បែរផ្ទៃទឹកនិងលើផ្ទៃស្លឹកដែលមានពណ៌បៃតងប្រផេះ បន្ទាប់មក ប្រែជាប្រផេះស្រាលមានគែមជុំវិញពណ៌ត្នោត។ នៅលើស្នាមរលាកមានវត្ថុមានដុំពកមូលតូចៗពណ៌ត្នោតក្រម៉ៅទៅខ្មៅ។ ជំងឺមានប្រភពមកពីដីតាមរយៈដុំស្ល័រ (sclerotum) ដែលបានបង្កើតឡើងដោយផ្សិតពីការបង្កជំងឺពីដំណាំដាំលើកមុន។

ជាធម្មតាដុំស្ក្លែរអណ្តែតទីលើផ្ទៃទឹកកំឡុងពេលរៀបចំដី។ ពេលប៉ះជាមួយដើមស្រូវ វាដុះចាក់ចូលទៅក្នុងស្រទបស្លឹកជាប់ផ្ទៃទឹកបន្ទាប់មករាលឡើងទៅលើ។ ជាធម្មតាផ្សិតបង្កជំងឺលើស្រូវនៅចុងដំណាក់កាលបែកគុម្ព ឬដើមដំណាក់កាលពន្លូតដើម។ ជំងឺអាចរាលដាលពីដើមមួយទៅមួយទៀតតាមរយៈស្លឹកប៉ះស្លឹក ឬស្លឹកប៉ះទៅនឹងស្រទបស្លឹក។ ផ្សិតលូតលាស់និងបង្កើតដុំផ្សិត បន្តទៅទៀត។



រូបភាព : រោគសញ្ញាបង្កឡើងដោយជំងឺរលាកស្រទបស្លឹកនៅលើស្លឹក និងស្រទបស្លឹក
ប្រភព : IRRI

### ១.៣.៨ ជំងឺម្រែងភ្លើង

**ឈ្មោះទូទៅជាភាសាខ្មែរ :** ជំងឺម្រែងភ្លើង
**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Kernel smut
**ឈ្មោះវិទ្យាសាស្ត្រ :** *Tilletia barclaya*
**គ្រួសារ :** Tilletiaceae

ការពិពណ៌នា :

ជាជំងឺធ្វើឱ្យ គ្រាប់ស្រូវ មានស្នាមជាំ ឬអុចៗនៅលើគ្រាប់ស្រូវ ឬគ្រាប់ស្រូវទាំងនោះផ្ទុះឡើង។ រោគសញ្ញានៃជំងឺនេះ ឃើញមាននៅលើគ្រាប់ស្រូវនៃកួរស្រូវ ហើយមានពណ៌ខ្មៅ ដូចធ្យូង ហើយស្ងៀតគ្មានគ្រាប់ស្រូវ។ ផ្សិតនេះអាចធ្វើចលនាតាមខ្យល់ តាមទឹក និងអាចឆ្លងទៅរុក្ខជាតិផ្សេងទៀតតាមរយៈការប៉ះទង្គិច។ ជំងឺនេះលេចចេញឡើងឱ្យយើងឃើញនៅពេលស្រូវចាប់ផ្តើមដាក់ម្សៅ។ ប្រភពដែលបណ្តាលឱ្យកើតជំងឺនេះគឺដីស្រែដែលដែលមានជ្រុះគ្រាប់ស្រូវមានជំងឺ ហើយភ្នាក់ងារបង្ករបស់វាអាចរស់នៅក្នុងស្រែបានប្រមាណ៦ខែ។



រូបភាព៖ រោគសញ្ញាបង្កឡើងដោយជំងឺម្រែងភ្លើងនៅលើគួរ និងគ្រាប់ស្រូវ
ប្រភព៖ IRRI

### ១.៣.៩ ជំងឺអុចត្នោតវែង

| | |
|---|---|
| **ឈ្មោះទូទៅជាភាសាខ្មែរ :** | ជំងឺអុចត្នោតវែង |
| **ឈ្មោះទូទៅជាភាសាអង់គ្លេស :** | Rice narrow brown spot |
| **ឈ្មោះវិទ្យាសាស្ត្រ :** | *Sphaerulina oryzina* |
| **គ្រួសារ :** | Mycosphaerellaceae |

ការពិពណ៌នា :

ជំងឺនេះច្រើនកើតនៅលើស្លឹក ស្រទបស្លឹក និងកួរស្រូវ។ វាកើតឡើងចាប់ពីដំណាក់បែកគុម្ព រហូតដល់ប្រមូលផល ប៉ុន្តែគេសង្កេតឃើញថាវាបំផ្លាញខ្លាំងនៅដំណាក់កាលកំណាកំណើតកួរ។ ជាដំបូងវាលេចឡើងនូវស្នាមអុចទ្រវែង ពណ៌ត្នោត មានប្រវែងពី ២-១០ម.ម និងទទឹង១-១.៥ម.ម។ ជំងឺនេះក៏អាចបណ្តាលឱ្យស្រទបស្លឹកខូចទ្រង់ទ្រាយ និងបាត់បង់ជាតិពណ៌ដែរ។ ពេលខ្លះជំងឺអុចត្នោតវែង អាចច្រឡំគ្នាជាមួយជំងឺបាក់តេរីឆ្នូតស្លឹក។



រូបភាព: ជំងឺរលួយអុចត្នោតវែង
ប្រភព: IRRI

### ១.៣.១០ ជំងឺរលាកស្លឹក

| | |
|---|---|
| **ឈ្មោះទូទៅជាភាសាខ្មែរ :** | ជំងឺរលាកស្លឹក |
| **ឈ្មោះទូទៅជាភាសាអង់គ្លេស :** | Rice leaf scald |
| **ឈ្មោះវិទ្យាសាស្ត្រ :** | *Microdochium oryzae* |
| **គ្រួសារ :** | Hyponectriaceae |

ការពិពណ៌នា:

ជំងឺនេះកើតនៅ ចុងរដូវដែលបំផ្លាញខ្លាំងលើស្លឹកស្រូវចាស់ និងអំណោយផលនៅរដូវវស្សានៅពេលដែលមានសំណើមបរិយាកាសខ្ពស់ ការប្រើប្រាស់ជីអាសូតលើសកម្រិត និងដាំញឹកពេក។ វា រាលដាលលឿននៅលើស្លឹកស្រូវដែលរងរបួស ជាងស្លឹកស្រូវដែលគ្មានរបួស។ ប្រភពចម្លងរបស់ជំងឺនេះ គឺគ្រាប់ពូជដែលកើតជំងឺ និងកាកសំណល់រុក្ខជាតិ។ ជាដំបូងនៅលើស្លឹកស្រូវមានលេចស្នាមអុចតូចពណ៌ត្នោតនៅផ្នែកខាងចុង និងលើគែមនៃស្លឹកស្រូវ បន្ទាប់មកស្នាមអុចនេះរីកធំឡើងៗដែលមានប្រវែងប្រហែល ១-៥ស.ម និងទទឹង ០.៥-១ស.ម ដែលអាចគ្របដណ្តប់លើផ្ទៃស្លឹកទាំងមូល។ ជំងឺនេះអាចច្រឡំគ្នាជាមួយនឹងជំងឺបាក់តេរីស្រពោនស្លឹកដែរ។ ដើម្បីបញ្ជាក់ពីប្រភេទជំងឺនេះ យើងត្រូវកាត់ស្លឹកស្រូវដែលកើតជំងឺ ដាក់ចូលទៅក្នុងទឹកដែលថ្លា ទុករយៈពេលប្រហែល៥-១០នាទី ប្រសិនបើមិនឃើញមានទឹកអន្លាយ (Ooz) ចេញពីស្លឹកនោះទេ វាគឺជាជំងឺរលាកស្លឹក ។



## ១.៤. ជំងឺបង្កឡើងដោយបាក់តេរី

### ១.៤.១ ជំងឺបាក់តេរីរលាកស្លឹក

ឈ្មោះទូទៅជាភាសាខ្មែរ : ជំងឺបាក់តេរីរលាកស្លឹក

ឈ្មោះទូទៅជាភាសាអង់គ្លេស : Bacterial leaf blight

ឈ្មោះវិទ្យាសាស្ត្រ : *Xanthomonas oryzae* pv. *oryzae*

គ្រួសារ : Xanthomonadaceae

ការពិពណ៌នា :

រោគសញ្ញានៃជំងឺនេះ យើងសង្កេតឃើញ តាមបណ្ដោយ នៃផ្ទៃស្លឹកទាំងសងខាងមានស្នាមឆ្នូតស្ងួតពណ៌លឿងប្រផេះឆ្នូត ។ រោគសញ្ញានេះភាគច្រើនកើតនៅពេលស្រូវមានកំណរកំណើតគួរ។ លើសពីនេះទៀតនៅពេលអាកាសធាតុមានលក្ខណៈសើម យើងអាចមើលឃើញជំងឺនេះតាមដំណក់ទឹកដែលមានលក្ខណៈសើមកខ្វក់ ពណ៌លឿងប្រផេះដូចក្រញ៉ូមបារី។ នៅពេលអាកាសធាតុមានលក្ខណៈសមស្រប យើងសង្កេតឃើញនៅលើស្លឹកមានចំណុចដាមពណ៌ប្រផេះស្ងួត ហើយចំណុចនេះបន្តិចម្ដងៗ ក៏ប្រែពណ៌ទៅជាលឿងស្លេតមានលក្ខណៈភ្លឺរលោង ដែលនៅទីបំផុតដាមទាំងនេះ ក្លាយទៅជាស្ងួតរលោងដូចហ្វីលថត។



រូបភាព : រោគសញ្ញាជំងឺបាក់តេរីស្រពោនបំផ្លាញលើស្លឹកស្រូវ

ប្រភព : Chin Khoon Min -Crop Protection Compendium

### ១.៤.២ ជំងឺបាក់តេរីឆ្នូតស្លឹក

**ឈ្មោះទូទៅជាភាសាខ្មែរ :** ជំងឺបាក់តេរីឆ្នូតស្លឹក

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Bacterial leaf streak

**ឈ្មោះវិទ្យាសាស្ត្រ :** *Xanthomonas oryzae* pv. *oryzicola*

**គ្រួសារ :** Xanthomonadaceae

ការពិពណ៌នា :

រោគសញ្ញានៃជំងឺនេះ យើងសង្កេតឃើញនៅលើស្លឹកមានដានស្នាមឆ្នូតវែងតាមបណ្តោយស្លឹកមានពណ៌ត្នោតក្រម៉ៅ ហើយស្នាមទាំងនេះនឹងរីកធំឡើងៗពាសពេញផ្ទៃស្លឹក។ លើសពីនេះទៀតនៅពេលស្លឹកស្រូវសើម យើងសង្កេតឃើញមានដំណក់ទឹកល្អក់ និងចំណុចពងពណ៌លឿងនៅលើស្លឹក ភ្នាក់ងារបង្កនៃជំងឺបាត់តេរីនេះគឺ *Xanthomonas oryzae pv.oryzicola* ដែលមានរាងមូលជារង្វង់ ហើយមានទំហំ ០.៥-០.៨ មីក្រូម៉ែត្រ X ១.២-៣.៥ មីក្រូម៉ែត្រ។

សីតុណ្ហភាពមធ្យមសម្រាប់ការរីកលូតលាស់គឺ ២៩ អង្សាសេ ហើយបាត់តេរីទាំងនេះនឹងងាប់នៅសីតុណ្ហភាព ៥០ ទៅ ៥១ អង្សាសេ។ ការជ្រៀតចូលនៃភ្នាក់ងារបង្កនេះទៅក្នុងគ្រាប់ស្រូវនៅដំណាក់កាលស្រូវដាក់ទឹកដោះ តាមរយៈការប៉ះទង្គិចគ្នាតាមការបញ្ចេញបញ្ចូលទឹក និងតាមគ្រាប់ពូជ។



រូបភាព : រោគសញ្ញាកើតឡើងនៅលើស្លឹកស្រូវចាប់ពីដំណាក់កាលដំបូងរហូតដល់ដំណាក់កាលធ្ងន់ធ្ងរ
ប្រភព : T.W. Mew/IRRI

### ១.៤.៣ ជំងឺបាក់តេរីរលួយស្រទបស្លឹកពណ៌ត្នោត

ឈ្មោះទូទៅជាភាសាខ្មែរ : ជំងឺបាក់តេរីរលួយស្រទបស្លឹកពណ៌ត្នោត
ឈ្មោះទូទៅជាភាសាអង់គ្លេស : **Bacterial sheath brown rot**
ឈ្មោះវិទ្យាសាស្ត្រ : *Pseudomonas fuscovaginae*
គ្រួសារ : **Pseudomonadaceae**

ការពិពណ៌នា :



រូបភាព : រោគសញ្ញារលួយកួរស្រូវ
ប្រភព : Rice Knowledge Bank



រូបភាព : រោគសញ្ញាជំងឺបាក់តេរីរលួយត្នោតស្រទបស្លឹក
ប្រភព : Rice Knowledge Bank

ជំងឺនេះអាចកកើតឡើងនៅក្នុងតំបន់ ដែលមានកម្ពស់ទឹកសមុទ្រខ្ពស់ (១២០០ - ១៧០០ ម៉ែត្រ លើកម្រិតទឹកសមុទ្រ) សីតុណ្ហភាពទាប (២០-២២°c) និងមានសំណើមខ្ពស់ទាំងលក្ខខណ្ឌសីតុណ្ហភាព និងលក្ខខណ្ឌត្រូពិក។ ជាពិសេសជំងឺត្រូវបានស្គាល់ថាកកើតឡើងនៅអាស៊ី អាមេរិកខាងត្បូងនិងអាមេរិកកណ្ដាល និងអាហ្វ្រិកខាងកើត រួមទាំងប្រទេស Madagascar ។

ជំងឺបាក់តេរីរលួយស្រទបស្លឹកពណ៌ត្នោតបណ្ដាលមកពីបាក់តេរី *Pseudomonas fuscovaginae* ដែលបណ្ដាលឱ្យរលួយនៅក្នុងស្រទបស្លឹក និងគ្រាប់ស្រូវ និងដើមស្រូវពេញវ័យ។ រោគសញ្ញារបស់វាកកើតឡើងនៅលើស្រទបស្លឹកទង់ជ័យនៅដំណាក់កាលផើមនៅលើកួរស្រូវ ហើយនៅដំណាក់កាលកូនសំណាប ការប្រែពណ៌កើតឡើងនៅ ដែលរាលដាលដល់ទ្រនុងស្លឹក ឬសរសៃវ៉ែននៃស្លឹក។

### ១.៤.៤ ជំងឺបាក់តេរីរលាកគ្រាប់

ឈ្មោះទូទៅជាភាសាខ្មែរ : ជំងឺបាក់តេរីរលាកគ្រាប់

ឈ្មោះទូទៅជាភាសាអង់គ្លេស : **Bacterial panicle blight**

ឈ្មោះវិទ្យាសាស្ត្រ : ***Burkholderia glumae***

គ្រួសារ : **Burkholderiaceae**

ការពិពណ៌នា :



រូបភាព រោគសញ្ញានៃការបំផ្លាញរបស់ជំងឺបាក់តេរីរលាកគ្រាប់

ប្រភព: https://www.uaex.edu/publications/pdf/FSA-7580.pdf

រោគសញ្ញានៃជំងឺបាក់តេរីរលាកគ្រាប់ភាគច្រើនបំផ្លាញញឹកញាប់ ដែលមានរលាកនៅផ្នែកគ្រាប់ស្រូវ ដែលការលេចឡើងដំបូងមានពណ៌សទៅពណ៌ប្រផេះភ្លឺ និងមានពណ៌ត្នោតចាស់នៅតាមគែមនៅផ្នែកខាងក្រោមនៃការលូតលាស់របស់គ្រាប់ស្រូវ។ ទងកួរស្រូវស្ថិតនៅពណ៌បៃតងកំឡុងពេលមានការបំផ្លាញដំបូង បន្ទាប់មកកួរស្រូវប្រែពណ៌ទៅជាពណ៌ដូចចំបើង ហើយថែមទាំងមានពណ៌ក្រម៉ៅនៅខាងចុងនៃកួរស្រូវ។ ការបំផ្លាញធ្ងន់ធ្ងរនៅគ្រាប់ស្រូវដែលធ្វើឱ្យគ្រាប់ស្រូវស្វិត និងធ្វើគ្រាប់ស្កៀត ហើយដើមបៃកអាចវិវឌ្ឍន៍ទៅជាពណ៌ត្នោតចាស់លើជាលិកាស្រទបស្លឹកទង់ជ័យ។ ដើមបៃកគុម្ពមួយចំនួនអាចមានការបំផ្លាញធ្ងន់ធ្ងរ ហើយជំងឺនេះអាចនឹងច្រឡំនឹងការបំផ្លាញដោយសារខ្យល់ ស្ត្រេសដោយសារទឹក ឬកត្តាបរិស្ថានផ្សេងៗ និងការបំផ្លាញដោយសារសត្វល្អិត(ដង្កូវស៊ីរូងដើម)។

## ១.៥. ជំងឺបង្កឡើងដោយវីរុស

### ១.៥.១ ជំងឺតឿស្មៅ

ឈ្មោះទូទៅជាភាសាខ្មែរ : ជំងឺតឿស្មៅ

ឈ្មោះទូទៅជាភាសាអង់គ្លេស : Grassy stunt

ឈ្មោះវិទ្យាសាស្ត្រ : Rice grassy stunt virus

អំបូរ : Tenuivirus

ការពិពណ៌នា :

រោគសញ្ញានៃជំងឺនេះ គឺយើងសង្កេតឃើញដើមស្រូវដុះបែកគុម្ពមានចំនួនច្រើន ចង្អៀត និងតឿតូចៗខុសប្រក្រតី តែមានពណ៌បៃតងជាងស្រូវដែលកើតជំងឺលឿងទុំ។ ភ្នាក់ងារចម្លងជំងឺនេះ គឺពពួកមមាចត្នោត (*Nilaparvata lugens*)។ តាមការសិក្សាបានបង្ហាញថាចំនួនដង់ស៊ីតេមមាចត្នោតដែលមានចាប់ពី ២០-៤០% អាចមានលទ្ធភាពចម្លងជំងឺវីរុសប្រភេទនេះទៅលើដំណាំស្រូវបានយ៉ាងងាយ។ ម្យ៉ាងទៀតពពួកមមាចត្នោតអាចមានលទ្ធភាពចម្លងជំងឺក្រោយពេលជញ្ជក់ដើមស្រូវដែលមានជំងឺរយៈពេល ៣០នាទី ហើយវីរុសនឹងឆ្លងចូលទៅសំងំនៅក្នុងសរីរាង្គពពួកមមាចត្នោតប្រមាណ ១០-១១ថ្ងៃ និងអាចចម្លងទៅរុក្ខជាតិផ្សេងទៀតតាមរយៈពពួកមមាចត្នោតដែលបានជញ្ជក់ដើមស្រូវផ្សេងទៀត ក្នុងរយៈពេល ៥-១៥នាទី។



រូបភាព : រោគសញ្ញាបង្កឡើងដោយជំងឺតឿស្មៅ

ប្រភព : IRRI

### ១.៥.២ ជំងឺត្បៀវញស្លឹក

**ឈ្មោះទូទៅជាភាសាខ្មែរ :** ជំងឺតឿវញស្លឹក

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Ragged stunt

**ឈ្មោះវិទ្យាសាស្ត្រ :** *Rice ragged stunt virus*

**គ្រួសារ :** Reoviridae

ការពិពណ៌នា :

រោគសញ្ញានៃជំងឺនេះ គេសង្កេតឃើញដើមមានលក្ខណៈតឿវញស្លឹក សសៃវែង ឡើងប៉ោងនៅលើស្លឹក និង ស្រទាប់ក្បែរកួរស្រូវ។ ជាទូទៅស្រូវមានលក្ខណៈរួញ រមួរនៅផ្នែកខាងលើ។ ហើយបន្ទាប់មកស្លឹកទាំងនេះ ប្រែពណ៌ពីលឿងទៅលឿងត្នោត ដែលជាបុព្វហេតុធ្វើឱ្យស្លឹកស្រូវទាំងនេះងាយបាក់។



រូបភាព: រោគសញ្ញាបង្កឡើងដោយជំងឺតឿវញស្លឹក
ប្រភព: IRRI

### ១.៥.៣ ជំងឺវីរុសទុងគ្រោ

**ឈ្មោះទូទៅជាភាសាខ្មែរ :** ជំងឺវីរុសទុងគ្រោ

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Tungro disease

**ឈ្មោះវិទ្យាសាស្ត្រ :** *Rice tungro bacilliform virus*

**គ្រួសារ :** Caulimoviridae

ការពិពណ៌នា :

ជំងឺនេះបង្កអោយដើមស្រូវតឿ និងបែកគុម្ពបានតិច។ តែបើសិនជំងឺនេះកើតឡើងនៅក្រោយពេលអាយុកាលស្រូវបាន ៦០ថ្ងៃនោះវានឹងលេចចេញនូវរោគសញ្ញាផ្សេងទៀត ដូចជាស្លឹកពណ៌លឿងខ្ចី ប្រែទៅជាពណ៌លឿងទឹកក្រូច។ នៅលើស្លឹកខ្ចីមានស្នាមអុចៗពណ៌ទឹកក្រូចចំរុះ ដែលលេចចេញពីផ្នែកចុងស្លឹក។ ចំពោះស្លឹកចាស់វិញ

លេចចេញនូវចំណុចតូចៗពណ៌ច្រេះមានទំហំផ្សេងៗគ្នា ដែលជាហេតុធ្វើឱ្យដើមស្រូវចេញផ្កាយឺតមានកួរតូច និងគ្មានដាក់គ្រាប់។

ភ្នាក់ងារបង្ករោគចម្លងជំងឺនេះ គឺពពួកមមាចត្នោតបៃតង Green leafthopper ដែលមានលទ្ធភាពក្នុងការចម្លងជំងឺពីដើមស្រូវមួយទៅដើមស្រូវមួយទៀត។ មមាចបៃតងដែលបានជញ្ជក់រុក្ខរសលើរុក្ខជាតិ ដែលមានផ្ទុកជំងឺវីរុសអាចចម្លងទៅរុក្ខជាតិដទៃទៀតក្នុងរយៈពេល ១-៥ថ្ងៃ និងលេចចេញនូវរោគសញ្ញាលើរុក្ខជាតិចម្លងក្រោយពេលដែលវីរុសត្រូវបានចម្លងទៅរុក្ខជាតិនោះក្នុងរយៈពេល៧-១០ថ្ងៃ។



រូបភាព : រោគសញ្ញាបង្កឡើងដោយជំងឺទុងគ្រោ
ប្រភព : IRRI

**១.៦. ជំងឺបង្កឡើងដោយណេម៉ាតូត**

**១.៦.១. ជំងឺណេម៉ាតូតដើមស្រូវ**

**ឈ្មោះទូទៅជាភាសាខ្មែរ** ជំងឺណេម៉ាតូតដើមស្រូវ

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Rice stem nematode

**ឈ្មោះវិទ្យាសាស្ត្រ :** *Ditylenchus angustus*

**គ្រួសារ :** Anguinidae

ការពិពណ៌នា :

នៅដំណាក់កាលលូតលាស់ ណេម៉ាតូតធ្វើអោយមានបណ្តុំទីតាំងនៃការបំផ្លាញ ដូចជាមានការឡើងពណ៌ស ឬខ្មៅនៅតាមគល់នៃដង្កៀបស្លឹកខ្ចីៗ។ ក្រោយមកស្នាមនេះប្រែជាពណ៌ត្នោត និងត្នោតក្រម៉ៅ។ ដង្កៀបស្លឹកប្រែជារមូររួញខូចទ្រង់ទ្រាយដើម និងថ្នាំងខាងក្រោមប្រែជាប៉ោងខុសប្រក្រតី។ ក្រោយមកកួរផ្ការួញមិនដាក់គ្រាប់ និងស្លឹកទង់ជ័យរួញរមូរមិនអាចចេញបាន។ ណេម៉ាតូតដែលបង្កជំងឺនេះ ធ្វើអោយដើមស្រូវកាត់បន្ថយការលូតលាស់ ដូចជាកំពស់ដើម និងអត្រាធ្វើរស្មីសំយោគចេញពីស្លឹក។ ណេម៉ាតូតប្រភេទនេះអាចរកឃើញនៅក្នុងគ្រាប់ស្រូវស្រស់ដែលប្រមូលចេញពីស្រែភ្លាមៗ ប៉ុន្តែកម្រប្រទះឃើញនៅក្នុងគ្រាប់ស្រូវដែលស្ងួតខូចនៅក្នុងស្រែ។


រូបភាពៈ ណេម៉ាតូតពេញវ័យ
ប្រភពៈ CABI


រូបភាពៈ រោគសញ្ញានៅដំណាក់កាលស្រូវធើម
ប្រភពៈ John Bridge/CABI BioScience


រូបភាពៈ រោគសញ្ញាលើដំណាំស្រូវ
ប្រភពៈ John Bridge/CABI BioScience

### ១.៦.២ ជំងឺណេម៉ាតូតពកឫសស្រូវ

| | |
|---|---|
| **ឈ្មោះទូទៅជាភាសាខ្មែរ :** | ជំងឺណេម៉ាតូតពកឫសស្រូវ |
| **ឈ្មោះទូទៅជាភាសាអង់គ្លេស :** | Rice root-knot nematode |
| **ឈ្មោះវិទ្យាសាស្ត្រ :** | *Meloidogyne graminicola* |
| **គ្រួសារ :** | Heteroderidae |

ការពិពណ៌នា :

ជាប្រភេទណេម៉ាតូតដែលធ្វើការបំផ្លាញយ៉ាងខ្លាំង ហើយត្រូវបានគេចាត់ទុកជាបញ្ហាសំខាន់ដែរនៅក្នុងផលិតកម្មដំណាំស្រូវ។ គេសង្កេតឃើញណេម៉ាតូតប្រភេទនេះមានវត្តមាននៅក្នុងប្រទេសកម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា ហ្វីលីពីន និងថៃជាដើម។ ដើមស្រូវដែលរងការបំផ្លាញមានលក្ខណៈតឿ ក្រិន មិនបែកគុម្ព ស្លឹកមានពណ៌លឿងទុំនៅផ្នែកខាងចុង ហើយអណ្តែតនៅលើផ្ទៃទឹកដែលធ្វើឱ្យកសិករមួយចំនួនហៅថាជំងឺប្រាច់។ លើសពីនេះមានលេចចេញយ៉ាងច្បាស់នូវស្នាមពកលើឫសស្រូវ។ នៅពេលដើមស្រូវទទួលរងការបំផ្លាញធ្ងន់ធ្ងរ គឺធ្វើឱ្យស្រូវនោះចេញផ្កា និងទុំឆាប់ហើយស្លឹកមានលក្ខណៈខ្ទុកខ្ទី។



## ១.៦.៣ ជំងឺណេម៉ាតូតសរចុងស្លឹកទង់ជ័យ

ឈ្មោះទូទៅជាភាសាខ្មែរ : ជំងឺណេម៉ាតូតសចុងស្លឹកទង់ជ័យ

ឈ្មោះទូទៅជាភាសាអង់គ្លេស : White Tip Nematode

ឈ្មោះវិទ្យាសាស្ត្រ : *Aphelenchoides besseyi*

គ្រួសារ : Aphelenchoididae

ការពិពណ៌នា :

ណេម៉ាតូត *Aphelenchoides besseyi* គឺជាពពួកកើតលើគ្រាប់ស្រូវ និងអាចបង្កជំងឺសរចុងស្លឹកទង់ជ័យ។ គេសង្កេតឃើញការបំផ្លាញមាននៅក្នុងប្រទេសជាច្រើននៅលើពិភពលោករួមមាន អីរ៉ង់ អ៊ីតាលី និងតួគីជាដើម ។ ណេម៉ាតូតនេះឆ្លងរាលពេញស្រែដោយសារគ្រាប់ពូជដែលមានផ្ទុកពួកវា។ នៅក្រោយពេលសាបគ្រាប់លើដីសើម ពួកវាចាប់ ផ្តើមមានសកម្មភាព និងចុចជញ្ជក់យករុក្ខរសពីរុក្ខជាតិនៅតាមថ្នាំងនៃគល់ និងកើនឡើងខ្លាំងនៅចុងដំណាក់កាលបែកគុម្ព។ ណេម៉ាតូតចូលក្នុងផ្កាស្រូវមុនពេលផ្កាបង្កកំណើត និងចុចជញ្ជក់រុក្ខរសពីអូវែ លំអង និងអំប្រីយ៉ុងនៅក្នុងផ្កា។ នៅពេលដែលគ្រាប់ស្រូវដាក់ទឹកដោះ និងម្សៅ ណេម៉ាតូតវិវត្តន៍ក្លាយជាសត្វពេញវ័យ ហើយចាប់ផ្តើមប្រមូលផ្តុំគ្នា និងក្រាំងនៅក្នុងគ្រាប់ស្រូវនោះ និងអាចក្រាំងបាននៅក្នុងគ្រាប់ស្រូវពី ៨ខែ ទៅ៣ឆ្នាំ ក្រោយពេលប្រមូលផលរួច តែពួកវាមិនអាចរស់នៅក្នុងដីបានយូរទេ។ ជាទូទៅវត្តមានពពួកណេម៉ាតូត ស្ថិតនៅលើគ្រាប់ស្រូវនៅផ្នែកកណ្តាលនៃកួរ។ សីតុណ្ហភាពសមស្របសម្រាប់ការបង្កកំណើត និងញាស់ នៃពងណេម៉ាតូត គឺ ៣០ អង្សាសេ។ នៅក្នុងលក្ខខណ្ឌសីតុណ្ហភាព ៣០អង្សាសេ វដ្តជីវិតណេម៉ាតូតមានរយៈពេលត្រឹមតែ ៨-១២ថ្ងៃប៉ុណ្ណោះ និងត្រូវការសំណើមបរិយាកាសលើសពី ៧០% ដើម្បីរស់ និងបម្លាស់ទីទៅកាន់កួរស្រូវ ។ កម្រិតផលប៉ះពាល់ដល់ច្រកទ្វារសេដ្ឋកិច្ច នៃណេម៉ាតូត គឺ ៣០០ក្បាល/១០០គ្រាប់ស្រូវ ។ ណេម៉ាតូតប្រភេទនេះធ្វើអោយទិន្នផលថយចុះចំនួន ៤,៩% នៅសហរដ្ឋអាមេរិច ពី ១០-៣០% នៅប្រទេសជប៉ុន ៤៥-៥០% នៅប្រទេសចិន និងនៅប្រទេសថៃច្រើនជាង៥០%។





# ផ្នែកទី២
# ដំណាំបន្លែយកផ្លែ

## ២. ដំណាំបន្លែយកផ្លែ

### ២.១ សត្វល្អិតចង្រៃលើដំណាំបន្លែយកផ្លែ

#### ២.១.១. ម៉ៃ

ឈ្មោះទូទៅជាភាសាខ្មែរ : ម៉ៃ

ឈ្មោះទូទៅជាភាសាអង់គ្លេស : Mites

គ្រួសារ : Eriophyidae

ការពិពណ៌នា :

**ពង:** តូចល្អិត រាងមូល មានពណ៌សថ្លា ទៅពណ៌លឿងស្រអាប់។

**មិនទាន់ពេញវ័យ:** ទ្រង់ទ្រាយ និងពណ៌ប្រហាក់ប្រហែលទៅនឹងមេពេញវ័យ ប៉ុន្តែទំហំតូចជាង។

**មេពេញវ័យ:** មានពណ៌ស ទៅពណ៌លឿង និងមានប្រវែងប្រហែល ០,២មម។



វដ្ដជីវិតម៉ៃ

ម៉ៃចាក់បញ្ចូលសារធាតុពុល នៅពេលវាស៊ីចំណី ដែលនោះរឹតតែបង្កើនការបំផ្លាញ។ ជាធម្មតាគេឃើញការបំផ្លាញដំបូងរបស់វា នៅលើត្រួយបណ្ដាលឱ្យរមួល និងឡើងពណ៌ ទង់ដែង។ ការបង្ហាញជាដំបូងនូវការរុករានរបស់ម៉ៃ គឺមានពណ៌ទឹកប្រាក់ លើស្លឹកខាងក្រោមៗ ហើយក្លាយទៅជាពណ៌ ទង់ដែងមុននឹងជ្រុះ។ ការបំផ្លាញរាលដាលដល់ ដើមដំណាំ។ មែកប៉េងប៉ោះបាត់បង់រោម នៅលើ ផ្ទៃរបស់វា ហើយក្លាយទៅជាភ្លឺផ្លេក រលោង និងពណ៌ត្នោត។ ផ្លែងាយចាញ់កំដៅព្រះអាទិត្យដោយសារការបាត់បង់ស្លឹក។ ម៉ៃ អាចបញ្ចេញសំណាញ់ព័ទ្ធពីលើដើម និងស្លឹកមានស្នាមអុចៗ ពណ៌ស នៅកន្លែងវាស៊ី។

## ២.១.២ ម៉ៃខ្លួនកំប៉ោង

**ឈ្មោះទូទៅជាភាសាខ្មែរ :** ម៉ៃខ្លួនកំប៉ោង

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Broad mite

**ឈ្មោះវិទ្យាសាស្ត្រ :** *Polyphagotarsonemus latus*

**គ្រួសារ :** Eriophyidae

**ការពិពណ៌នា :**

**ពង:** តូចល្អិត រាងមូល មានពណ៌សថ្លា ទៅពណ៌លឿងស្រអាប់។

**មិនទាន់ពេញវ័យ:** ទ្រង់ទ្រាយ និងពណ៌ប្រហាក់ប្រហែលទៅនឹងមេពេញវ័យ ប៉ុន្តែទំហំតូចជាង។

**មេពេញវ័យ:** មានពណ៌ស ទៅពណ៌លឿង និងមានប្រវែងប្រហែល ០,២មម។ មានរាងពងក្រពើ និងមានពណ៌ក្រហមខ្មៅ។

**ការបំផ្លាញ:** វាចាក់បញ្ចូលសារជាតុពុល នៅពេលវាស៊ីចំណី ដែលនោះរឹតតែបង្កើនការបំផ្លាញ។ ជាទូទៅគេប្រទះឃើញវាមាននៅត្រង់ចំណុចលូតលាស់នានា។ ផ្លែងាយចាញ់កំដៅព្រះអាទិត្យ ដោយសារការបាត់បង់ស្លឹក។



ម៉ៃខ្លួនកំប៉ោង និងរោគសញ្ញាលើផ្លែម្ទេសប្លោក

## ២.១.៣ ម៉ៃពីងពាងសណ្តែក

**ឈ្មោះទូទៅជាភាសាខ្មែរ :** ម៉ៃពីងពាងសណ្តែក

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Bean Spider mite

**ឈ្មោះវិទ្យាសាស្ត្រ :** *Tetranychus ludeni*

**គ្រួសារ :** Eriophyidae

**ការពិពណ៌នា :**

**ពង:** តូចល្អិត រាងមូល មានពណ៌សថ្លា ទៅពណ៌លឿងស្រអាប់។

**មិនទាន់ពេញវ័យ:** ទ្រង់ទ្រាយ និងពណ៌ប្រហាក់ប្រហែលទៅនឹងមេពេញវ័យ ប៉ុន្តែទំហំតូចជាង។

**មេពេញវ័យ:** មានទំហំ ធំជាងគឺ០.៥មម។ ខ្លួនរបស់វាមានពណ៌ក្រហមខ្មៅ។

**ការបំផ្លាញ:** ជាធម្មតាគេឃើញការបំផ្លាញដំបូងរបស់វា នៅលើត្រួយបណ្តាលឲ្យរមួល និងឡើងពណ៌ទង់ដែង។ ការបង្ហាញជាដំបូងនូវការរុករានរបស់វា មានពណ៌ទឹកប្រាក់ លើស្លឹកខាងក្រោមៗ ហើយក្លាយទៅជាពណ៌

ទង់ដែងមុននឹងជ្រុះ។ ការបំផ្លាញរាលដាលដល់ ដើមដំណាំ។ មែកប៉េងប៉ោះបាត់បង់រោម នៅលើ ផ្លែរបស់វា ហើយក្លាយទៅជាក្លឺផ្លេក រលោង និងពណ៌ត្នោត។ ផ្លែងាយចាញ់កំដៅព្រះអាទិត្យ ដោយសារការបាត់បង់ស្លឹក។ អាចបញ្ចេញសំណាញ់ព័ទ្ធពីលើដើម និងស្លឹកមានស្នាមអុចៗ ពណ៌ស នៅកន្លែងវាស៊ី។



ម៉ៃពីងពាងសណ្តែក និងការបំផ្លាញរបស់

២.១.៤ ម៉ៃអុចពីរ

**ឈ្មោះទូទៅជាភាសាខ្មែរ :** ម៉ៃអុចពីរ

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Two-spotted mite

**ឈ្មោះវិទ្យាសាស្ត្រ :** *Tetranychus urticae*

**គ្រួសារ :** Eriophyidae

**ការពិពណ៌នា :**

**ពង:** តូចល្អិត រាងមូល មានពណ៌សថ្លា ទៅពណ៌លឿងស្រអាប់។

**មិនទាន់ពេញវ័យ:** ទ្រង់ទ្រាយ និងពណ៌ប្រហាក់ប្រហែលទៅនឹងមេពេញវ័យ ប៉ុន្តែទំហំតូចជាង។

**មេពេញវ័យ:** មានទំហំ ធំជាងគឺ០.៥មម។ ខ្លួនរបស់ វាមានពណ៌ បៃតងលឿង និងមានចំណុចខ្មៅពីរ ស្លាបម្ខាងៗមានចំណុចខ្មៅមួយ។

**ការបំផ្លាញ:** ជាធម្មតាគេឃើញការបំផ្លាញដំបូងរបស់វា នៅលើត្រួយបណ្តាលឲ្យរមួល និងឡើងពណ៌ ទង់ដែង។ ការបង្ហាញជាដំបូងនូវការរុករានរបស់វា គឺមានពណ៌ទឹកប្រាក់ លើស្លឹកខាងក្រោមៗ ហើយក្លាយទៅជាពណ៌ ទង់ដែងមុននឹងជ្រុះ។ ការបំផ្លាញរាលដាលដល់ ដើមដំណាំ។ មែកប៉េងប៉ោះបាត់បង់រោម នៅលើផ្លែរបស់វា ហើយក្លាយទៅជាក្លឺផ្លេក រលោង និងពណ៌ត្នោត។ វាអាចបញ្ចេញសំណាញ់ព័ទ្ធពីលើដើម និងស្លឹកមានស្នាមអុចៗ ពណ៌ស នៅកន្លែងវាស៊ី។



ម៉ៃមានអុចពីរ និងការបំផ្លាញរបស់វា

### ២.១.៥ ម៉ៃច្រេះប៉េងប៉ោះ

ឈ្មោះទូទៅជាភាសាខ្មែរ : ម៉ៃច្រេះប៉េងប៉ោះ

ឈ្មោះទូទៅជាភាសាអង់គ្លេស : Tomato russet mite

ឈ្មោះវិទ្យាសាស្ត្រ : *Aculops lycopersici*

គ្រួសារ : Eriophyidae

**ការពិពណ៌នា :**

**ពង:** តូចល្អិត រាងមូល មានពណ៌សថ្លា ទៅពណ៌លឿងស្រអាប់។

**មិនទាន់ពេញវ័យ:** ទ្រង់ទ្រាយ និងពណ៌ប្រហាក់ប្រហែលទៅនឹងមេពេញវ័យ ប៉ុន្តែទំហំតូចជាង។

**មេពេញវ័យ:** មានពណ៌ស ទៅពណ៌លឿង និងមានប្រវែងប្រហែល ០,២មម។ ខ្លួនរបស់វាមានរាងជ្រុង។

**ការបំផ្លាញ:** ជាធម្មតាគេឃើញការបំផ្លាញដំបូងរបស់វា នៅលើត្រួយបណ្តាលឲ្យរមួល និងឡើងពណ៌ ទង់ដែង។ ការបង្ហាញជាដំបូងនូវការរុករានរបស់វា គឺមានពណ៌ទឹកប្រាក់ លើស្លឹកខាងក្រោមៗ ហើយក្លាយទៅជាពណ៌ ទង់ដែងមុននឹងជ្រុះ។ ការបំផ្លាញរាលដាលដល់ ដើមដំណាំ។ មៃកប៉េងប៉ោះបាត់បង់រោម នៅលើផ្ទៃរបស់វា ហើយក្លាយទៅជាភ្លឺផ្លេក រលោង និងពណ៌ត្នោត។ ផ្លែងាយចាញ់កំដៅព្រះអាទិត្យ ដោយសារការបាត់បង់ស្លឹក។



ម៉ៃច្រេះប៉េងប៉ោះ និងការបំផ្លាញរបស់វា

### ២.១.៦. ទ្រីប

ឈ្មោះទូទៅជាភាសាខ្មែរ : ទ្រីប

ឈ្មោះទូទៅជាភាសាអង់គ្លេស : Thrips

ឈ្មោះវិទ្យាសាស្ត្រ : *Thrip palmi*

គ្រួសារ : Thripidae

ការពិពណ៌នា :

**ពង:** មេទ្រីបពងដាក់ចូលទៅក្នុងជាលិកាស្លឹក កំពុងលូតលាស់ខ្លាំង កញ្ចុំផ្កា និងផ្លែកំពុងលូតលាស់។

**មិនទាន់ពេញវ័យ:** ដង្កូវគ្មានស្លាប មានពណ៌ស ឬពណ៌លឿងព្រលែត ដែលមានដងខ្លួនទ្រវែង ប្រវែងប្រហែល ០,៥-១ មម។

**មេពេញវ័យ:** ទ្រីបគឺជាសត្វល្អិតតូចបំផុតមាន រាងដូចគ្រាប់បែក និងមានប្រវែងប្រហែល ១-១,៥មម។ វាមានស្លាបពីរគូរ មានរោមឆ្មារៗ នៅជុំវិញគែមស្លាប។ ទ្រីបមានពណ៌ និងទំហំខុសៗគ្នា អាស្រ័យទៅតាមប្រភេទរបស់វា។



វដ្តជីវិតទ្រីប

ការបំផ្លាញដោយស៊ី លេចឡើងនូវពណ៌ទឹកប្រាក់ និងស្នាមអុចៗ នៅលើស្លឹកកូនដំណាំ។ ដើមដែលទទួលការរុករានខ្លាំង មានលក្ខណៈពណ៌ទឹកប្រាក់ ឬពណ៌ទង់ដែងនៅលើស្លឹក ស្លឹកក្រិន និងលែងចេញពន្លក ហើយផ្លែខុសទ្រង់ទ្រាយ និងមានស្នាម។

### ២.១.៧ ទ្រីបលើផ្កា

**ឈ្មោះទូទៅជាភាសាខ្មែរ :** ទ្រីបលើផ្កា

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Western flower thrips

**ឈ្មោះវិទ្យាសាស្ត្រ :** *Franklinniella occidentalis*

**គ្រួសារ :** Thripidae

**ការពិពណ៌នា :**

**ពង:** មេទ្រីបពងដាក់ចូលទៅក្នុងជាលិកាស្លឹក កំពុងលូតលាស់ខ្លាំង កញ្ចុំផ្កា និងផ្លែកំពុងលូតលាស់។

**មិនទាន់ពេញវ័យ:** ដង្កូវគ្មានស្លាប មានពណ៌ស ឬពណ៌លឿងព្រលែត ដែលមានដងខ្លួនទ្រវែង ប្រវែងប្រហែល ០,៥-១ មម។

**មេពេញវ័យ:** ទ្រីបគឺជាសត្វល្អិតតូចបំផុតមាន រាងដូចគ្រាប់បែក និងមានប្រវែងប្រហែល ១-១,៥មម។ វាមានស្លាបពីរគូរ មានរោមឆ្មារៗ នៅជុំវិញគែមស្លាប។ ទ្រីបមានពណ៌ និងទំហំ ខុសៗគ្នា អាស្រ័យទៅតាមប្រភេទរបស់វា។

**ការបំផ្លាញ:** ការបំផ្លាញដោយស៊ី លេចឡើងនូវពណ៌ទឹកប្រាក់ និងស្នាមអុចៗ នៅលើស្លឹកកូនដំណាំ។ ដើមដែលទទួលការរុករានខ្លាំង មានលក្ខណៈពណ៌ទឹកប្រាក់ ឬពណ៌ទង់ដែងនៅលើស្លឹក, ស្លឹកក្រិន និងលែងចេញពន្លក ហើយផ្លែខុសទ្រង់ទ្រាយ និងមានស្នាម។


ទ្រីបលើផ្កា និងការបំផ្លាញរបស់វា

### ២.១.៨ ទ្រីបប៉េងប៉ោះ

ឈ្មោះទូទៅជាភាសាខ្មែរ : ទ្រីបប៉េងប៉ោះ
ឈ្មោះទូទៅជាភាសាអង់គ្លេស : Tomato thrips
ឈ្មោះវិទ្យាសាស្ត្រ : *Franklinniella schultzei*
គ្រួសារ : Thripidae

ការពិពណ៌នា :
**ពង:** មេទ្រីបពងដាក់ចូលទៅក្នុងជាលិកាស្លឹក កំពុងលូតលាស់ខ្លាំង កញ្ចុំផ្កា និងផ្លែកំពុងលូតលាស់។
**មិនទាន់ពេញវ័យ:** ដង្កូវគ្មានស្លាប មានពណ៌ស ឬពណ៌លឿងព្រលែត ដែលមានដងខ្លួនទ្រវែង ប្រវែងប្រហែល ០,៥-១ មម។
**មេពេញវ័យ:** ទ្រីបគឺជាសត្វល្អិតតូចបំផុតមាន រាងដូចគ្រាប់បែក និងមានប្រវែងប្រហែល ១-១,៥មម។ វាមានស្លាបពីរគូ មានរោមឆ្មារៗ នៅជុំវិញគែមស្លាប។ ទ្រីបមានពណ៌ និងទំហំ ខុសៗគ្នា អាស្រ័យទៅតាមប្រភេទរបស់វា។
**ការបំផ្លាញ:** ការបំផ្លាញដោយស៊ី លេចឡើងនូវពណ៌ទឹកប្រាក់ និងស្នាមអុចៗ នៅលើស្លឹកកូនដំណាំ។ ដើមដែលទទួលការរុករានខ្លាំង មានលក្ខណៈពណ៌ទឹកប្រាក់ ឬពណ៌ទង់ដែងនៅលើស្លឹក, ស្លឹកក្រិន និងលែងចេញពន្លក ហើយផ្លែខុសទ្រង់ទ្រាយ និងមានស្នាម។



ទ្រីបប៉េងប៉ោះ និងការបំផ្លាញរបស់វា

### ២.១.៩ ទ្រីបម្ទេស

ឈ្មោះទូទៅជាភាសាខ្មែរ : ទ្រីបម្ទេស
ឈ្មោះទូទៅជាភាសាអង់គ្លេស : Chilli thrips
ឈ្មោះវិទ្យាសាស្ត្រ : *Scirtothrips dorsalis*
គ្រួសារ : Thripidae

ការពិពណ៌នា :
**ពង:** មេទ្រីបពងដាក់ចូលទៅក្នុងជាលិកាស្លឹក កំពុងលូតលាស់ខ្លាំង កញ្ចុំផ្កា និងផ្លែកំពុងលូតលាស់។
**មិនទាន់ពេញវ័យ:** ដង្កូវគ្មានស្លាប មានពណ៌ស ឬពណ៌លឿងព្រលែត ដែលមានដងខ្លួនទ្រវែង ប្រវែងប្រហែល ០,៥-១ មម។

**មេពេញវ័យៈ** ទ្រីបគឺជាសត្វល្អិតតូចបំផុតមាន រាងដូចគ្រាប់បែក និងមានប្រវែងប្រហែល ១-១,៥មម។ វាមានស្លាបពីរគូរ មានរោមឆ្មារៗ នៅជុំវិញគែមស្លាប។ ទ្រីបមានពណ៌ និងទំហំ ខុសៗគ្នា អាស្រ័យទៅតាមប្រភេទរបស់វា។

**ការបំផ្លាញៈ** ការបំផ្លាញដោយស៊ី លេចឡើងនូវពណ៌ទឹកប្រាក់ និងស្នាមអុចៗ នៅលើស្លឹកកូនដំណាំ។ ដើមដែលទទួលការរុករានខ្លាំង មានលក្ខណៈពណ៌ទឹកប្រាក់ ឬពណ៌ទង់ដែងនៅលើស្លឹក, ស្លឹកក្រិន និងលែងចេញពន្លក ហើយផ្លែខុសទ្រង់ទ្រាយ និងមានស្នាម។



ទ្រីបម្ទេស និងការបំផ្លាញរបស់វា

២.១.១០ ទ្រីបចង្រៃ

| | |
|---|---|
| ឈ្មោះទូទៅជាភាសាខ្មែរ : | ទ្រីបចង្រៃ |
| ឈ្មោះទូទៅជាភាសាអង់គ្លេស : | Plague thrips |
| ឈ្មោះវិទ្យាសាស្ត្រ : | *Thrips imagines* |
| គ្រួសារ : | Thripidae |

**ការពិពណ៌នា :**

**ពងៈ** មេទ្រីបពងដាក់ចូលទៅក្នុងជាលិកាស្លឹក កំពុងលូតលាស់ខ្លាំង កញ្ចុំផ្កា និងផ្លែកំពុងលូតលាស់។

**មិនទាន់ពេញវ័យៈ** ដង្កូវគ្មានស្លាប មានពណ៌ស ឬពណ៌លឿងព្រលែត ដែលមានដងខ្លួនទ្រវែង ប្រវែងប្រហែល ០,៥-១ មម។

**មេពេញវ័យៈ** ទ្រីបគឺជាសត្វល្អិតតូចបំផុតមាន រាងដូចគ្រាប់បែក និងមានប្រវែងប្រហែល ១-១,៥មម។ វាមានស្លាបពីរគូរ មានរោមឆ្មារៗ នៅជុំវិញគែមស្លាប។ ទ្រីបមានពណ៌ និងទំហំ ខុសៗគ្នា អាស្រ័យទៅតាមប្រភេទរបស់វា។

**ការបំផ្លាញៈ** ការបំផ្លាញដោយស៊ី លេចឡើងនូវពណ៌ទឹកប្រាក់ និងស្នាមអុចៗ នៅលើស្លឹកកូនដំណាំ។ ដើមដែលទទួលការរុករានខ្លាំង មានលក្ខណៈពណ៌ទឹកប្រាក់ ឬពណ៌ទង់ដែងនៅលើស្លឹក, ស្លឹកក្រិន និងលែងចេញពន្លក ហើយផ្លែខុសទ្រង់ទ្រាយ និងមានស្នាម។



ទ្រីបចង្រៃ

២.១.១១ ទ្រីបត្រសក់ផ្អែម

ឈ្មោះទូទៅជាភាសាខ្មែរ : ទ្រីបត្រសក់ផ្អែម

ឈ្មោះទូទៅជាភាសាអង់គ្លេស : Melon thrips

ឈ្មោះវិទ្យាសាស្ត្រ : *Thrips palmi*

គ្រួសារ : Thripidae

**ការពិពណ៌នា :**

**ពង:** មេទ្រីបពងដាក់ចូលទៅក្នុងជាលិកាស្លឹក កំពុងលូតលាស់ខ្លាំង កញ្ចុំផ្កា និងផ្លែកំពុងលូតលាស់។

**មិនទាន់ពេញវ័យ:** ដង្កូវគ្មានស្លាប មានពណ៌ស ឬពណ៌លឿងព្រលែត ដែលមានដងខ្លួនទ្រវែង ប្រវែងប្រហែល ០,៥-១ មម។

**មេពេញវ័យ:** ទ្រីបគឺជាសត្វល្អិតតូចបំផុតមាន រាងដូចគ្រាប់បែក និងមានប្រវែងប្រហែល ១-១,៥មម។ វាមានស្លាបពីរគូរ មានរោមឆ្មារៗ នៅជុំវិញគែមស្លាប។ ទ្រីបមានពណ៌ និងទំហំ ខុសៗគ្នា អាស្រ័យទៅតាមប្រភេទរបស់វា។

**ការបំផ្លាញ:** ការបំផ្លាញដោយស៊ី លេចឡើងនូវពណ៌ទឹកប្រាក់ និងស្នាមអុចៗ នៅលើស្លឹកកូនដំណាំ។ ដើមដែលទទួលការរុករានខ្លាំង មានលក្ខណៈពណ៌ទឹកប្រាក់ ឬពណ៌ទង់ដែងនៅលើស្លឹក, ស្លឹកក្រិន និងលែងចេញពន្លក ហើយផ្លែខុសទ្រង់ទ្រាយ និងមានស្នាម។



ទ្រីបត្រសក់ផ្អែម និងការបំផ្លាញរបស់វា

២.១.១២. ចៃប៉េស្តបៃតង

ឈ្មោះទូទៅជាភាសាខ្មែរ : ចៃប៉េស្តបៃតង

ឈ្មោះទូទៅជាភាសាអង់គ្លេស : Green peach aphid

ឈ្មោះវិទ្យាសាស្ត្រ : *Myzus persicae*

គ្រួសារ : Aphididae

ការពិពណ៌នា :

**ពង:** ជាធម្មតា ចៃបង្កើតកូនរស់ ប៉ុន្តែវាអាចពងក្នុងឱកាសកម្រណាមួយបានដែរ។

**មិនទាន់ពេញវ័យ:** ចៃមិនទាន់ពេញវ័យ មានរូបរាងប្រហាក់ប្រហែលមេពេញវ័យដែរ។

**មេពេញវ័យ:** ចៃគឺជាសត្វល្អិតមានខ្លួនទន់ និងមានជើងប្រាំមួយ។ វាមានប្រវែងប្រហែល ២ ទៅ ៣មម។ ចៃអាចមានស្លាប ឬគ្មានស្លាប។ ស្លាប មានរាងដូចជាដំបូលគ្របពីលើពោះវា នៅពេលដែលវានៅស្ងៀម។ ពណ៌ មានភាពខុសគ្នារវាងប្រភេទនានា និងរវាងប្រភេទមានស្លាប និងអត់ស្លាប។ ជាធម្មតាមានពណ៌បៃតងខ្ចីទៅបៃតងចាស់។




ហ្វូងចៃក្នុងចំនួនច្រើន នៅក្នុងដំណាក់កាលកូនដំណាំ អាចបង្កឱ្យស្លឹករួញ ហើយស្លឹក ឬ ត្រួយ ងាប់មុនអាយុ។ ចំពោះដំណាំធំ ទិន្នផលអាចថយចុះ។ ចៃបន្សល់នូវសារធាតុ ស្អិតម្យ៉ាង ហៅថា ទឹកដមរុក្ខជាតិ(honeydew) នៅលើស្លឹក និងត្រួយ ដែលជួយ ជំរុញដល់ការលូតលាស់ផ្សិតពណ៌ខ្មៅ និង កាត់បន្ថយកម្លាំងលូតលាស់របស់ដើម។ ចៃក៏អាចចម្លងជំងឺវីរុសបំផ្លាញដើមដែរ នៅពេលវាស៊ី។

២.១.១៣ ចៃកប្បាស

ឈ្មោះទូទៅជាភាសាខ្មែរ : ចៃកប្បាស

ឈ្មោះទូទៅជាភាសាអង់គ្លេស : Cotton aphid

ឈ្មោះវិទ្យាសាស្ត្រ : *Aphis grossypii*

គ្រួសារ : Aphididae

**ការពិពណ៌នា :**

**ពង:** ជាធម្មតា ចៃបង្កើតកូនរស់ ប៉ុន្តែវាអាចពងក្នុងឱកាសកម្រណាមួយបានដែរ។

**មិនទាន់ពេញវ័យ:** ចៃមិនទាន់ពេញវ័យ មានរូបរាងប្រហាក់ប្រហែលមេពេញវ័យដែរ។

**មេពេញវ័យ:** ចៃ គឺជាសត្វល្អិតមានខ្លួនទន់ និងមានជើងប្រាំមួយ។ វាជាចៃតូចបំផុតដែលមានប្រវែងប្រហែល ២មម ចំណែកឯប្រភេទដទៃទៀតមានប្រវែងប្រហែល ៣មម។ ចៃអាចមានស្លាប ឬគ្មានស្លាប។ ស្លាប មានរាងដូចជាដំបូលគ្របពីលើពោះវា នៅពេលដែលវានៅស្ងៀម។ ពណ៌មានភាពខុសគ្នារវាងប្រភេទនានា និងរវាងប្រភេទមានស្លាប និងអត់ស្លាប។ ជាធម្មតាមានពណ៌បៃតងខ្ចីទៅបៃតងចាស់។

**ការបំផ្លាញ:** ហ្វូងចៃក្នុងចំនួនច្រើន នៅក្នុងដំណាក់កាលកូនដំណាំ អាចបង្កឲ្យស្លឹករួញ ហើយស្លឹក ឬ ត្រួយងាប់មុនអាយុ។ ចំពោះដំណាំធំ ទិន្នផលអាចថយចុះ។ ចៃ បន្សល់នូវសារធាតុ ស្អិតម្យ៉ាង ហៅថា ទឹកដមរុក្ខជាតិ(honeydew) នៅលើស្លឹក និងត្រួយ ដែលជួយ ជំរុញដល់ការលូតលាស់ផ្សិតពណ៌ខ្មៅ និង កាត់បន្ថយកម្លាំងលូតលាស់របស់ដើម។ ចៃ ក៏អាចចម្លងជំងឺវីរុសបំផ្លាញដើមដែរ នៅពេលវាស៊ី។



ចៃកប្បាស និងការបំផ្លាញរបស់វា

២.១.១៤ ចៃផ្កាកណ្ដឹង

| | |
|---|---|
| **ឈ្មោះទូទៅជាភាសាខ្មែរ :** | **ចៃផ្កាកណ្ដឹង** |
| **ឈ្មោះទូទៅជាភាសាអង់គ្លេស :** | Foxglove aphid |
| **ឈ្មោះវិទ្យាសាស្ត្រ :** | *Aulacorthum solani* |
| **គ្រួសារ :** | Aphididae |

**ការពិពណ៌នា :**

**ពង:** ជាធម្មតា ចៃបង្កើតកូនរស់ ប៉ុន្តែវាអាចពងក្នុងឱកាសកម្រណាមួយបានដែរ។

**មិនទាន់ពេញវ័យ:** ចៃមិនទាន់ពេញវ័យ មានរូបរាងប្រហាក់ប្រហែលមេពេញវ័យដែរ។

**មេពេញវ័យ:** ចៃ គឺជាសត្វល្អិតមានខ្លួនទន់ និងមានជើងប្រាំមួយ មានប្រវែងប្រហែល ៣មម។ ចៃអាចមានស្លាប ឬគ្មានស្លាប។ ស្លាបមានរាងដូចជាដំបូលគ្របពីលើពោះវា នៅពេលដែលវានៅស្ងៀម។ ពណ៌មានភាពខុសគ្នារវាងប្រភេទនានា និងរវាងប្រភេទមានស្លាប និងអត់ស្លាប។ មានពណ៌បៃតងលាយលឿង ទៅពណ៌ត្នោតស្ទើរ។

**ការបំផ្លាញ:** ហ្វូងចៃក្នុងចំនួនច្រើន នៅក្នុងដំណាក់កាលកូនដំណាំ អាចបង្កឲ្យស្លឹករួញ ហើយស្លឹក ឬ ត្រួយងាប់មុនអាយុ។ ចំពោះដំណាំធំ ទិន្នផលអាចថយចុះ។ ចៃ បន្សល់នូវសារធាតុ ស្អិតម្យ៉ាង ហៅថា ទឹកដមរុក្ខជាតិ(honeydew) នៅលើស្លឹក និងត្រួយ ដែលជួយ ជំរុញដល់ការលូតលាស់ផ្សិតពណ៌ខ្មៅ និង កាត់បន្ថយកម្លាំងលូតលាស់របស់ដើម។ ចៃ ក៏អាចចម្លងជំងឺវីរុសបំផ្លាញដើមដែរ នៅពេលវាស៊ី។



ចៃផ្កាកណ្ដឹង និងការបំផ្លាញរបស់វា

## ២.១.១៥ ចៃប៉េងប៉ោះ

**ឈ្មោះទូទៅជាភាសាខ្មែរ :** ចៃប៉េងប៉ោះ
**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Tomato aphid
**ឈ្មោះវិទ្យាសាស្ត្រ :** *Macrosiphum euphorbiae*
**គ្រួសារ :** Aphididae

**ការពិពណ៌នា :**

**ពង:** ជាធម្មតា ចៃបង្កើតកូនរស់ ប៉ុន្តែវាអាចពងក្នុងឱកាសកម្រណាមួយបានដែរ។
**មិនទាន់ពេញវ័យ:** ចៃមិនទាន់ពេញវ័យ មានរូបរាងប្រហាក់ប្រហែលមេពេញវ័យដែរ។
**មេពេញវ័យ:** ចៃ គឺជាសត្វល្អិតមានខ្លួនទន់ និងមានជើងប្រាំមួយ។ មានប្រវែងប្រហែល ៣មម។ ចៃអាចមានស្លាប ឬគ្មានស្លាប។ ស្លាប មានរាងដូចជាដំបូលគ្របពីលើពោះវា នៅពេលដែលវានៅស្ងៀម។ ពណ៌មានភាពខុសគ្នារវាងប្រភេទនានា និងរវាងប្រភេទមានស្លាប និងអត់ស្លាប។ មានពណ៌បៃតងខ្ចីលាយជាមួយពណ៌ផ្កាឈូកព្រឿងៗ។
**ការបំផ្លាញ:** ហ្វូងចៃក្នុងចំនួនច្រើន នៅក្នុងដំណាក់កាលកូនដំណាំ អាចបង្កឲ្យស្លឹករួញ ហើយស្លឹក ឬ ត្រួយងាប់មុនអាយុ។ ចំពោះដំណាំធំ ទិន្នផលអាចថយចុះ។ ចៃ បន្សល់នូវសារធាតុ ស្អិតម្យ៉ាង ហៅថា ទឹកដមរុក្ខជាតិ (honeydew) នៅលើស្លឹក និងត្រួយ ដែលជួយជំរុញដល់ការលូតលាស់ផ្សិតពណ៌ខ្មៅ និង កាត់បន្ថយកម្លាំងលូតលាស់របស់ដើម។ ចៃ ក៏អាចចម្លងជំងឺវីរុសបំផ្លាញដើមដែរ នៅពេលវាស៊ី។



ចៃប៉េងប៉ោះ

## ២.១.១៦. មមាចស្លឹក

ឈ្មោះទូទៅជាភាសាខ្មែរ : មមាចស្លឹក

ឈ្មោះទូទៅជាភាសាអង់គ្លេស : Leaf hopper

ឈ្មោះវិទ្យាសាស្ត្រ : *Austroasca viridigrisea*

គ្រួសារ : Cicadellidae

ការពិពណ៌នា :

**ពង:** មានពណ៌ស្លេក រាងទ្រវែង ហើយពងដាក់ ទៅក្នុងជាលិកាស្លឹក។

**មិនទាន់ពេញវ័យ:** មានពណ៌ស្លេក ពីសទៅ បៃតង មានក្បាលមូល ឬ ស្រួច។ រូបរាង ស្រដៀងនឹងមេពេញវ័យ។

**មេពេញវ័យ:** មានរាងជ្រុង មានពណ៌ផ្សេងៗគ្នា ទៅតាមប្រភេទអាចជា ពណ៌ស ឬពណ៌ត្នោត បៃតង ឬលឿង។ ជើងខាងក្រោយសម្រាប់លោត។ ដុះស្លាបរាងដូច ដំបូលផ្ទះនៅពីលើពោះ។




នៅគ្រប់ដំណាក់កាលទាំងអស់ វាជញ្ជក់រុក្ខរស។ ការបំផ្លាញមានលក្ខណៈ ប្រហាក់ប្រហែលទៅនឹងការបំផ្លាញបង្កដោយ ទ្រីប ឬម៉ែ។ ស៊ីចិញ្ចឹមខ្លួននៅផ្ទៃស្លឹក ផ្នែកខាងក្រោម បង្កឱ្យស្លឹករមួល និងធ្វើឱ្យក្រិនដល់ ការលូតលាស់ថ្មី។ ជារឿយៗ វាបន្សល់ទុកអាចម៍ នៅពីក្រោយវា ដែលមានស្នាមអុចពណ៌ខ្មៅ។ ដំណាំដែលទទួលការរុករានយ៉ាងខ្លាំង ក្លាយទៅជាក្រិន និងពណ៌ប្រផេះ។ ផ្លែអាចត្រូវបំផ្លាញ ដែលធ្វើឱ្យមានស្នាមអុចៗ ពណ៌ស ស្រអាប់។



*Austroasca viridigrisea* ពេញវ័យ



*Austroasca viridigrisea* ពេញវ័យ



*Austroasca* កូនទើបញាស់

### ២.១.១៧ មមាចស្លឹកកប្បាស

**ឈ្មោះទូទៅជាភាសាខ្មែរ :** មមាចស្លឹកកប្បាស
**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Cotton leafhopper
**ឈ្មោះវិទ្យាសាស្ត្រ :** *Amrasca devastans*
**គ្រួសារ :** Cicadellidae

**ការពិពណ៌នា :**
**ពង:** មានពណ៌ស្លេក រាងទ្រវែង ហើយពងដាក់ ទៅក្នុងជាលិកាស្លឹក។
**មិនទាន់ពេញវ័យ:** មានពណ៌ស្លេក ពីសទៅ បៃតង មានក្បាលមូល ឬ ស្រួច។ រូបរាង ស្រដៀងនឹងមេពេញវ័យ។
**មេពេញវ័យ:** ឧស្សាហ៍ខ្លាំង។ មានរាងជ្រុង មានពណ៌ផ្សេងៗគ្នា ទៅតាមប្រភេទ អាចជា ពណ៌ស ឬពណ៌ត្នោត បៃតង ឬលឿង។ ជើងខាងក្រោយសម្រាប់លោត។ ដុះស្លាបរាងដូច ដំបូលផ្ទះនៅពីលើពោះ។
**ការបំផ្លាញ:** នៅគ្រប់ដំណាក់កាលទាំងអស់ វាជញ្ជក់រុក្ខរស។ ការបំផ្លាញមានលក្ខណៈ ប្រហាក់ប្រហែលទៅនឹងការបំផ្លាញបង្កដោយ ទ្រីប ឬម៉ៃ។ ស៊ីចិញ្ចឹមខ្លួននៅផ្ទៃស្លឹក ផ្នែកខាង ក្រោម បង្កឲ្យស្លឹករមូល និងធ្វើឲ្យក្រិនដល់ ការលូតលាស់ថ្មី។ ជារឿយៗ វាបន្សល់ទុកអាចម៍ នៅពីក្រោយវា ដែលមានស្នាមអុចពណ៌ខ្មៅ។ ដើមដំណាំដែលទទួលការរុករានយ៉ាងខ្លាំង ក្លាយទៅជាក្រិន និងពណ៌ប្រផេះ។ ផ្លែអាចត្រូវ បំផ្លាញដែលធ្វើឲ្យមានស្នាមអុចៗ ពណ៌ស ស្រអាប់។



មមាចស្លឹកកប្បាស និងការបំផ្លាញរបស់វា

### ២.១.១៨ មមាចស្លឹកពណ៌ត្នោត

**ឈ្មោះទូទៅជាភាសាខ្មែរ :** មមាចស្លឹកពណ៌ត្នោត
**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Common brown leafhopper
**ឈ្មោះវិទ្យាសាស្ត្រ :** *Orosius orientalis*
**គ្រួសារ :** Cicadellidae

**ការពិពណ៌នា :**
**ពង:** មានពណ៌ស្លេក រាងទ្រវែង ហើយពងដាក់ ទៅក្នុងជាលិកាស្លឹក។
**មិនទាន់ពេញវ័យ:** មានពណ៌ស្លេក ពីសទៅ បៃតង មានក្បាលមូល ឬ ស្រួច។ រូបរាង ស្រដៀងនឹងមេពេញវ័យ។

**មេពេញវ័យ:** ឧស្សាហ៍ខ្លាំង។ មានរាងជ្រុង មានពណ៌ផ្សេងៗគ្នា ទៅតាមប្រភេទ អាចជា ពណ៌ស ឬពណ៌ត្នោត បៃតង ឬលឿង។ ជើងខាងក្រោយសម្រាប់លោត។ ដុះស្លាបរាងដូច ដំបូលផ្ទះនៅពីលើពោះ។

**ការបំផ្លាញ:** នៅគ្រប់ដំណាក់កាលទាំងអស់ វាជញ្ជក់រុក្ខរស។ ការបំផ្លាញមានលក្ខណៈ ប្រហាក់ប្រហែលទៅនឹងការបំផ្លាញបង្កដោយ ទ្រីប ឬម៉ៃ។ ស៊ីចិញ្ចឹមខ្លួននៅផ្ទៃស្លឹក ផ្នែកខាង ក្រោម បង្កឲ្យស្លឹករមួល និងធ្វើឲ្យក្រិនដល់ ការលូតលាស់ថ្មី។ ជារឿយៗ វាបន្សល់ទុកអាចម៍ នៅពីក្រោយវា ដែលមានស្នាមអុចពណ៌ខ្មៅ។ ដើមដំណាំដែលទទួលការរុករានយ៉ាងខ្លាំង ក្លាយទៅជាក្រិន និងពណ៌ប្រផេះ។ ផ្លែអាចត្រូវ បំផ្លាញ ដែលធ្វើឲ្យមានស្នាមអុចៗ ពណ៌ស ស្រអាប់។



មមាចស្លឹកពណ៌ត្នោត និងការបំផ្លាញរបស់វា



ការបំផ្លាញនៅលើស្លឹកប៉េងប៉ោះ ការបំផ្លាញនៅលើស្លឹកប៉េងប៉ោះ ការបំផ្លាញនៅលើស្លឹកត្រប់

២.១.១៩. រុយស

ឈ្មោះទូទៅជាភាសាខ្មែរ : រុយស

ឈ្មោះទូទៅជាភាសាអង់គ្លេស : **Whiteflies**

គ្រួសារ : Aleyrodidae

**ការពិពណ៌នា:**

**ពង:** តូចមានពណ៌បៃតងលឿង ប្តូរទៅជា ពណ៌ត្នោតនៅពេលជិតញាស់។ ពងដាក់ ខាងក្រោមស្លឹក។

**មិនទាន់ពេញវ័យ:** កូនរាងពងក្រពើមានពណ៌សបៃតង។ ដុកឌឿ មានពណ៌លឿង មានរោមបន្ទាប់បន្សំ។

**មេពេញវ័យ:** មានប្រវែងប្រហែល ១-១,៥មម និងមានរូបរាងដូចពពួកមេអំបៅដែលមាន ស្លាបពណ៌ស។




**ការបំផ្លាញៈ** រុយសជញ្ជក់រុក្ខរសពីដើម។ ការរុករាន ធ្ងន់ធ្ងរអាចធ្វើឱ្យដំណាំលូតលាស់ខ្សោយ ស្លឹកឡើងពណ៌លឿង និងដើមបាត់បង់កម្លាំង លូលាស់ ។ ទឹកដមរុក្ខជាតិ(honeydew) ត្រូវបាន ផលិតចេញមក ជម្រុញឱ្យមានការដុះផ្សិតពណ៌ ខ្មៅ ដែលកាន់តែកាត់បន្ថយកម្លាំងលូតលាស់ របស់ដើម។

## ២.១.២០ រុយសរង្វង់

ឈ្មោះទូទៅជាភាសាខ្មែរ : រុយសរង្វង់
ឈ្មោះទូទៅជាភាសាអង់គ្លេស : Spiraling whitefly
ឈ្មោះវិទ្យាសាស្ត្រ : *Aleurodicus disperses*
គ្រួសារ : Aleyrodidae

ការពិពណ៌នា :
**ពង:** តូចមានពណ៌បៃតងលឿង ប្តូរទៅជា ពណ៌ត្នោតនៅពេលជិតញាស់។ ពងដាក់ ខាងក្រោមស្លឹក។
**មិនទាន់ពេញវ័យ:** កូនរាងពងក្រពើមានពណ៌សបៃតង។ ដុកឌឿ មានពណ៌លឿង មានរោមបន្ទាប់បន្សំ។
**មេពេញវ័យ:** មានប្រវែងប្រហែល ១-១,៥មម និងមានរូបរាងដូចពពួកមេអំបៅដែលមាន ស្លាបពណ៌ស។
**ការបំផ្លាញៈ** ជញ្ជក់រុក្ខរសពីដើម។ ការរុករាន ធ្ងន់ធ្ងរអាចធ្វើឲ្យដំណាំលូតលាស់ខ្សោយ ស្លឹកឡើងពណ៌លឿង និងដើមបាត់បង់កម្លាំង លូលាស់ ។ ទឹកដមរុក្ខជាតិត្រូវបាន ផលិតចេញមក ជម្រុញឲ្យមានការដុះផ្សិតពណ៌ខ្មៅ ដែលកាន់តែកាត់បន្ថយកម្លាំងលូតលាស់ របស់ដើម។



រុយសរង្វង់ និងការបំផ្លាញរបស់វា

## ២.១.២១ រុយសស្លឹកពណ៌ប្រាក់

ឈ្មោះទូទៅជាភាសាខ្មែរ : រុយសស្លឹកពណ៌ប្រាក់

ឈ្មោះទូទៅជាភាសាអង់គ្លេស : Silverleaf whitefly

ឈ្មោះវិទ្យាសាស្ត្រ : *Bemisia tabaci*

គ្រួសារ : Aleyrodidae

### ការពិពណ៌នា :

**ពង:** តូចមានពណ៌បៃតងលឿង ប្តូរទៅជា ពណ៌ត្នោតនៅពេលជិតញាស់។ ពងដាក់ ខាងក្រោមស្លឹក។

**មិនទាន់ពេញវ័យ:** កូនរាងពងក្រពើមានពណ៌សបៃតង។ ដុកឌឿ មានពណ៌លឿង មានរោមបន្ទាប់បន្សំ។

**មេពេញវ័យ:** មានប្រវែងប្រហែល ១-១,៥មម និងមានរូបរាងដូចពពួកមេអំបៅដែលមាន ស្លាបពណ៌ស។

**ការបំផ្លាញ:** ជញ្ជក់រុក្ខរសពីដើម។ ការរុករាន ធ្ងន់ធ្ងរអាចធ្វើឲ្យដំណាំលូតលាស់ខ្សោយ ស្លឹកឡើងពណ៌លឿង និងដើមបាត់បង់កម្លាំង លូលាស់ ។ ទឹកដមរុក្ខជាតិត្រូវបាន ផលិតចេញមក ជម្រុញឲ្យមានការដុះផ្សិតពណ៌ ខ្មៅ ដែលកាន់តែកាត់បន្ថយកម្លាំងលូតលាស់ របស់ដើម។



រុយសស្លឹកពណ៌ប្រាក់ និងការបំផ្លាញរបស់វា

### ២.១.២២ រុយសផ្ទះកញ្ចក់

**ឈ្មោះទូទៅជាភាសាខ្មែរ :** រុយសផ្ទះកញ្ចក់

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Greenhouse whitefly

**ឈ្មោះវិទ្យាសាស្ត្រ :** *Trialeurodes vaporariorum*

**គ្រួសារ :** Aleyrodidae

**ការពិពណ៌នា :**

**ពង:** តូចមានពណ៌បៃតងលឿង ប្តូរទៅជា ពណ៌ត្នោតនៅពេលជិតញាស់។ ពងដាក់ ខាងក្រោមស្លឹក។
**មិនទាន់ពេញវ័យ:** កូនរាងពងក្រពើមានពណ៌សបៃតង។ ដុកឌឿ មានពណ៌លឿង មានរោមបន្ទាប់បន្សំ។
**មេពេញវ័យ:** មានប្រវែងប្រហែល ១-១,៥មម និងមានរូបរាងដូចពពួកមេអំបៅដែលមាន ស្លាបពណ៌ស។
**ការបំផ្លាញ:** ជញ្ជក់រុក្ខរសពីដើម។ ការរុករាន ធ្ងន់ធ្ងរអាចធ្វើឲ្យដំណាំលូតលាស់ខ្សោយ ស្លឹកឡើងពណ៌លឿង និងដើមបាត់បង់កម្លាំង លូលាស់ ។ ទឹកដមរុក្ខជាតិ ត្រូវបាន ផលិតចេញមក ជម្រុញឲ្យមានការដុះផ្សិតពណ៌ ខ្មៅ ដែលកាន់តែកាត់បន្ថយកម្លាំងលូតលាស់របស់ដើម។



រុយសផ្ទះកញ្ចក់ និងការបំផ្លាញរបស់វា

### ២.១.២៣. ចៃម្សៅ

**ឈ្មោះទូទៅជាភាសាខ្មែរ :** ចៃម្សៅ

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Mealybugs

**ឈ្មោះវិទ្យាសាស្ត្រ :** *Paracoccus spp.*

**គ្រួសារ :** Pseudococcidae

ការពិពណ៌នា :

**ពង:** ចៃម្សៅញីទុកពងនៅក្នុងសំបុកពោះរបស់វា។
**មិនទាន់ពេញវ័យ:** កូនញាស់ដំណាក់កាលទីមួយ ហៅថា"ដង្កូវវារ" និងវារចេញពីមេវា ទៅរកកន្លែងថ្មីមួយនៅលើរុក្ខជាតិ ដើម្បីធ្វើជាជម្រករបស់វា។ នៅពេលមានជម្រកហើយ វាចាក់បញ្ចូលម្ជុលវែងនៃប្រអប់មាត់របស់វាចូលទៅក្នុងដើម និងជញ្ជក់ចិញ្ចឹមខ្លួនវា។ ចៃម្សៅមានចំនួន ៤-៥ ដំណាក់កាល។

**មេពេញវ័យ:** មេពេញវ័យញី មានរាងពងក្រពើ ប្រវែងប្រហែល៣-៦មម និង គ្របដណ្តប់ ដោយស្រទាប់ក្រមួនពណ៌ស ដែលជារឿយៗ មានសរសៃក្រមួននៅលើ គែមខ្លួន។ ចៃម្សៅ ឈ្មោល មានរូបមាឌតូចដូចចៃ(aphid) និងមិន ស៊ីអ្វីឡើយ។ពួកវាមានជីវិតខ្លី និងកម្របានឃើញណាស់។




ដើមរងនូវការរុករានក្លាយទៅជាក្រិន។ នៅលើដំណាំប៉េងប៉ោះ ចៃម្សៅធ្វើឱ្យខូចទ្រង់ទ្រាយ និងរំខានដល់ការលូតលាស់ត្រួយ ហើយនៅចុងក្រោយ ធ្វើឱ្យមែកនិងស្លឹករមួល និងរួញរាងជីប និងជ្រួញស្លឹក។ នៅពេលមានការកើតឡើងច្រើននៃចៃម្សៅនេះ កន្លែងដែលទទួលការរុករានធ្ងន់ធ្ងរ ឡើងពណ៌លឿង និងងាប់ (រួមទាំងការបាត់បង់កញ្ចុំផ្កា ផ្កា និងផ្លែខ្ចីៗ)។ ផ្សិតពណ៌ខ្មៅដុះយ៉ាងច្រើន នៅលើទឹកដមរុក្ខជាតិ ដែលចៃម្សៅផលិតឡើង។ ទឹកដមរុក្ខជាតិ ក៏អាចទាក់ទាញស្រមោចដែល អាចជួយការពារចៃម្សៅពីការវាយប្រហារដោយប្រេដាទ័រ និងឌីម៉ាល់ប៉ារ៉ាស៊ីត។



ការបំផ្លាញរបស់ចៃម្សៅលើដំណាំត្រប់

### ២.១.២៤ ចៃម្សៅល្ហុង

| | |
|---|---|
| **ឈ្មោះទូទៅជាភាសាខ្មែរ :** | **ចៃម្សៅល្ហុង** |
| **ឈ្មោះទូទៅជាភាសាអង់គ្លេស :** | Papaya Mealybug |
| **ឈ្មោះវិទ្យាសាស្ត្រ :** | *Paracoccus marginatus* |
| **គ្រួសារ :** | Pseudococcidae |

**ការពិពណ៌នា :**

**ពង:** ចៃម្សៅញីទុកពងនៅក្នុងសំបុកពោះរបស់វា។

**មិនទាន់ពេញវ័យ:** កូនញាស់ដំណាក់កាលទីមួយ ហៅថា"ដង្កូវវារ" និងវារចេញពីមេវា ទៅរកកន្លែងថ្មីមួយនៅលើរុក្ខជាតិ ដើម្បីធ្វើជាជម្រករបស់វា។ នៅពេលមានជម្រកហើយ វាចាក់បញ្ចូលម្ជុលវែងនៃប្រអប់មាត់របស់វា ចូលទៅក្នុងដើម និងជញ្ជក់ចិញ្ចឹមខ្លួនវា។ ចៃម្សៅមានចំនួន ៤-៥ ដំណាក់កាល។

**មេពេញវ័យ:** មេពេញវ័យញី មានរាងពងក្រពើ ប្រវែងប្រហែល៣-៦មម និង គ្របដណ្តប់ ដោយស្រទាប់ក្រមួនពណ៌ស ដែលជារឿយៗ មានសរសៃក្រមួននៅលើ គែមខ្លួន។ ចៃម្សៅ ឈ្មោល មានរូបមាឌតូចដូចចៃ (aphid) និងមិន ស៊ីអ្វីឡើយ។ពួកវាមានជីវិតខ្លី និងកម្របានឃើញណាស់។

**ការបំផ្លាញ:** ដើមរងនូវការរុករានក្លាយទៅជាក្រិន។ នៅលើដំណាំប៉េងប៉ោះ ចៃម្សៅធ្វើឲ្យខូចទ្រង់ទ្រាយ និងរំខានដល់ការលូតលាស់ត្រួយ ហើយនៅចុងក្រោយ ធ្វើឲ្យមែកនិងស្លឹករមួល និងរួញរាងជីប និងជ្រុញស្លឹក។ នៅពេលមានការកើតឡើងច្រើននៃចៃម្សៅនេះ កន្លែងដែលទទួលការរុករានធ្ងន់ធ្ងរ ឡើងពណ៌លឿង និងងាប់ (រួមទាំងការបាត់បង់កញ្ចុំផ្កា ផ្កា និងផ្លែខ្ចីៗ)។ ផ្សិតពណ៌ខ្មៅដុះយ៉ាងច្រើន នៅលើទឹកដមរុក្ខជាតិ ដែលចៃម្សៅផលិតឡើង។ ទឹកដមរុក្ខជាតិ ក៏អាចទាក់ទាញស្រមោចដែល អាចជួយការពារចៃម្សៅពីការវាយប្រហារដោយប្រេដាទ័រ និងឱម៉ាល់ប៉ារ៉ាស៊ីត។



ចៃម្សៅល្ហុង និងការបំផ្លាញរបស់វា

## ២.១.២៥ ចៃម្សៅកប្បាស

| | |
|---|---|
| ឈ្មោះទូទៅជាភាសាខ្មែរ : | ចៃម្សៅកប្បាស |
| ឈ្មោះទូទៅជាភាសាអង់គ្លេស : | Cotton Mealybug |
| ឈ្មោះវិទ្យាសាស្ត្រ : | *Phenacoccus solennopsis* |
| គ្រួសារ : | Pseudococcidae |

**ការពិពណ៌នា :**

**ពង:** ចៃម្សៅញីទុកពងនៅក្នុងសំបុកពោះរបស់វា។

**មិនទាន់ពេញវ័យ:** កូនញាស់ដំណាក់កាលទីមួយ ហៅថា"ដង្កូវវារ" និងវារចេញពីមេវា ទៅរកកន្លែងថ្មីមួយនៅលើរុក្ខជាតិ ដើម្បីធ្វើជាជម្រករបស់វា។ នៅពេលមានជម្រកហើយ វាចាក់បញ្ចូលម្ជុលវែងនៃប្រអប់មាត់របស់វា ចូលទៅក្នុងដើម និងជញ្ជក់ចិញ្ចឹមខ្លួនវា។ ចៃម្សៅមានចំនួន ៤-៥ ដំណាក់កាល។

**មេពេញវ័យ:** មេពេញវ័យញី មានរាងពងក្រពើ ប្រវែងប្រហែល៣-៦មម និង គ្របដណ្តប់ ដោយស្រទាប់ក្រមួនពណ៌ស ដែលជារឿយៗ មានសរសៃក្រមួននៅលើ គែមខ្លួន។ ចៃម្សៅ ឈ្មោល មានរូបមាឌតូចដូចចៃ (aphid) និងមិនស៊ីអ្វីឡើយ។ ពួកវាមានជីវិតខ្លី និងកម្របានឃើញណាស់។

**ការបំផ្លាញ:** ដើមរងនូវការរុករានក្លាយទៅជាក្រិន។ នៅលើដំណាំប៉េងប៉ោះ ចៃម្សៅធ្វើឲ្យខូចទ្រង់ទ្រាយ និងរំខានដល់ការលូតលាស់ត្រួយ ហើយនៅចុងក្រោយ ធ្វើឲ្យមែកនិងស្លឹករមួល និងរួញរាងជីប និងជ្រួញស្លឹក។ នៅពេលមានការកើតឡើងច្រើននៃចៃម្សៅនេះ កន្លែងដែលទទួលការរុករានធ្ងន់ធ្ងរ ឡើងពណ៌លឿង និងងាប់ (រួមទាំងការបាត់បង់កញ្ចុំផ្កា ផ្កា និងផ្លែខ្ចីៗ)។ ផ្សិតពណ៌ខ្មៅដុះយ៉ាងច្រើន នៅលើទឹកដមរុក្ខជាតិ ដែលចៃម្សៅផលិតឡើង។




ចៃម្សៅកប្បាស និងការបំផ្លាញរបស់វា

២.១.២៦ ស្រឹងរូខែរគ្លែន

**ឈ្មោះទូទៅជាភាសាខ្មែរ :** ស្រឹងរូខែរគ្លែន

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Rutherglen bug

**ឈ្មោះវិទ្យាសាស្ត្រ :** *Nysius vinitor*

**គ្រួសារ :** Lygaeidae

**ការពិពណ៌នា :**

**ពង:** ប្រវែង១មម និងមានពណ៌ក្រែម។ ពងជាចង្កោមដែលមានចំនួនប្រាំមួយ ដាក់ នៅលើចុងផ្កានៃស្មៅចង្រៃ ឬសំរាមនៅដី។

**មិនទាន់ពេញវ័យ:** រូបរាងប្រហាក់ប្រហែលនឹងមេពេញវ័យ។ កូនញាស់ធាត់ខ្លីមានពណ៌ត្នោតលឿងនៅពេលញាស់ ប៉ុន្តែបន្ទាប់មកភ្លាម ក្លាយជាពណ៌ខ្មៅ។

**មេពេញវ័យ:** ដងខ្លួនរាងវៀវ ពណ៌ត្នោតប្រផេះ មានភ្នែកពណ៌ខ្មៅ។ ស្លាបមានពណ៌ប្រាក់ បង្កើតជាក្រឡាដូចសញ្ញាខ្វែង នៅលើខ្នងរបស់វា។

**ការបំផ្លាញ:** មានចំនួនច្រើនជញ្ជក់ស្លឹក អាចបណ្តាលឲ្យដើមស្វិត។



ស្រឹងរូខេរក្លែន និងពងរបស់វា



ស្រឹងរូខេរក្លែន

## ២.១.២៧. ស្រឹងបៃតង

**ឈ្មោះទូទៅជាភាសាខ្មែរ :** ស្រឹងបៃតង

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Green vegetable bug

**ឈ្មោះវិទ្យាសាស្ត្រ :** *Nezara viridula*

**គ្រួសារ :** Pentatomidae

ការពិពណ៌នា :

**ពង:** ពណ៌លឿងស្លេក ទៅពណ៌ត្នោតក្រហម មានប្រវែងប្រហែល ១មម និងបញ្ឈរក្នុងចង្កោមណែនដែលមានប្រហែល ៤០-៨០ពង ក្នុងមួយចង្កោមៗ។

**មិនទាន់ពេញវ័យ:** កូនរូបរាងប្រហាក់ប្រហែលទៅ នឹងមេពេញវ័យ និងសក ៥ដងនៅចន្លោះ ពេលពង និងមេពេញវ័យ។ កូនញាស់នៅដំណាក់កាលដំបូងមានប្រវែងប្រហែល១,៥មម ហើយកូនញាស់នៅដំណាក់កាលបន្ទាប់មានទំហំកើនឡើង។ កូនញាស់មានស្នាមពណ៌ក្រហម បៃតង ខ្មៅ និងទឹកក្រូច។ កូនញាស់នៅដំណាក់កាលទីប្រាំភាគច្រើនមាន ពណ៌បៃតង។

**មេពេញវ័យ:** មេពេញវ័យមានពណ៌បៃតងភ្លឺ ជាលក្ខណៈឯកសណ្ឋាន និងមានប្រវែង ប្រហែល ១២-១៥ មម ដោយមានដងខ្លួនរាងដូចខែល។ មេពេញវ័យ រស់នៅក្នុង សិសិររដូវ អាចក្លាយទៅជាពណ៌ស្វាយ លាយត្នោត ក្នុងពេលសម្ងំស្ងៀមនៅសិសិររដូវ។




ធម្មជាតិនៃការបឺតរុក្ខរសរបស់ សមាសភាពចង្រៃនេះ បង្កឱ្យមានស្នាមរបួស ជាំទឹក បង្កើតជាភាពខុសទ្រង់ទ្រាយនៃការលូតលាស់នៅជុំវិញកន្លែងបំផ្លាញ។ ចំនួនស្រើងច្រើន កាត់បន្ថយកម្លាំងលូតលាស់របស់រុក្ខជាតិ។


មេពេញវ័យ


ពងទើបទម្លាក់ថ្មីៗ


កូនទើបញាស់


កូនទើបញាស់ដំណាក់កាលទី១


កូនទើបញាស់ដំណាក់កាលទី៣


កូនទើបញាស់ដំណាក់កាលទី៤



កូនទើបញាស់ដំណាក់កាលទី៥



រោគសញ្ញាបំផ្លាញលើផ្លែ

**២.១.២៨. ដង្កូវមេអំបៅជំឡូងបារាំង**

**ឈ្មោះទូទៅជាភាសាខ្មែរ :** **ដង្កូវមេអំបៅជំឡូងបារាំង**

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Potato moths

**ឈ្មោះវិទ្យាសាស្ត្រ :** *Phthorimaea operculella*

**គ្រួសារ :** Gelechiidae

ការពិពណ៌នា :

**ពង:** តូច រាងពងក្រពើ មានពណ៌សទឹកដោះ គោ។ ពងរាយមួយៗមួយដាក់លើស្លឹក។

**មិនទាន់ពេញវ័យ:** ពណ៌បៃតង ត្នោត ឬផ្កាឈូក

**មេពេញវ័យ:** មេអំបៅមានមាឌតូច ពណ៌ត្នោតប្រផេះ។ ចុងស្លាបខាងមុខ និងគែមស្លាបខាងក្រោយទាំងអស់មានដុះរោមវែងៗ។




ដង្កូវចោះរន្ធចូលទៅក្នុងចុងមែក និង ទំលុះចុះមកក្រោម បណ្តាលឱ្យងាប់ចុង និង ប៉ះពាល់ធ្ងន់ធ្ងរដល់ការលូតលាស់។ ដង្កូវអាចចោះរន្ធចូលទៅក្នុងផ្លែតាមចុងទង ឬនៅកន្លែងដែលផ្លែប៉ះគ្នា។ ចំពោះដើមចាស់ ដង្កូវបង្កើតស្នាមជាំក្នុងស្លឹក។



មេអំបៅពេញវ័យ



មេអំបៅពេញវ័យ



ដង្កូវ




ដង្កូវ និងដឹកដឿ



ការបំផ្លាញលើស្លឹក



ការបំផ្លាញលើផ្លែ

## ២.១.២៩. ដង្កូវហ្វូង

| | |
|---|---|
| ឈ្មោះទូទៅជាភាសាខ្មែរ : | ដង្កូវហ្វូង |
| ឈ្មោះទូទៅជាភាសាអង់គ្លេស : | Armyworm |
| ឈ្មោះវិទ្យាសាស្ត្រ : | *Spodoptera exigua* និង *S. litura* |
| គ្រួសារ : | Noctuidae |

ការពិពណ៌នា :

**ពង:** ពងជាចង្កោម និងរុំដោយស្រកាខ្លួនពណ៌ត្នោត

**មិនទាន់ពេញវ័យៈ** កូនដង្កូវមានពណ៌បៃតងស្លេក និងឡើងពណ៌ប្រផេះទៅពណ៌ត្នោតចាស់នៅពេលដែលវាធំ។ អេសអិល មានត្រីកោណពណ៌ខ្មៅពីរជួរ និងខ្សែពណ៌លឿង លេចចេញច្បាស់នៅតាមចំហៀងខ្លួនទាំងសងខាង។ ដង្កូវអេសអ៊ី មានខ្លួនរលោង និងមាន ពណ៌បៃតង និងឆ្នូតពណ៌លឿងស្លេក នៅតាម ដងខ្លួន។ ដង្កូវអាចមានស្នាមខ្មៅនៅលើអង្កត់ ទីបីនៃដងខ្លួន និងពណ៌ខ្មៅពេញនៅពេល វាពេញវ័យ។

**មេពេញវ័យៈ** ស្លាបមុខខ្មៅ មានលក្ខណៈជា ប្រភេទជាក់លាក់។ វាមានស្នាម មិន ជាក់លាក់ ពណ៌ស និងមានខ្សែនៅជាយស្លាប។ ស្លាបក្រោយមានពណ៌សដូចគុជ។




កូនដង្កូវស៊ីចំណីជាក្រុម បញ្ចេញនូវគ្រោងឆ្អឹងស្លឹក។ ដង្កូវធំរស់នៅតែឯង និងស៊ីផ្កា ស្លឹក និងត្រួយលូតលាស់របស់រុក្ខជាតិ។


កូនដង្កូវ *Spodoptera exigua*


ដង្កូវ *Spodoptera exigua*


ដឹកឌឿ *Spodoptera exigua*


*Spodoptera exigua* បំផ្លាញលើម្ទេស


មេអំបៅ *S. litura*


ពង *S. litura*



ការបំផ្លាញរបស់ *S. litura*



ដង្កូវ *S. litura*



មេអំបៅ *S. litura*

### ២.១.៣០. ដង្កូវបាក់ខ្នងកប្បាស

| | |
|---|---|
| ឈ្មោះទូទៅជាភាសាខ្មែរ : | ដង្កូវបាក់ខ្នងកប្បាស |
| ឈ្មោះទូទៅជាភាសាអង់គ្លេស : | Cotton semi-looper |
| ឈ្មោះវិទ្យាសាស្ត្រ : | *Anomis flava* |
| គ្រួសារ : | Noctuidae |

ការពិពណ៌នា :

**ពង:** ពងមានពណ៌បៃតងរាងខៀវស្លេក និងជាធម្មតា ពងរាយមួយៗនៅខាងក្រោមផ្ទៃស្លឹក។

**មិនទាន់ពេញវ័យ:** ដង្កូវមានពណ៌បៃតង មានប្រវែងរហូតដល់ ៤០មម និងអាចមានឆ្នូតពណ៌សនៅលើដងខ្លួន។ ដឹកឡើត្រូវបានប្រទះឃើញនៅក្នុងរមូរស្លឹក។

**មេពេញវ័យ:** មេអំបៅមានប្រវែង ២០មម និងមានស្លាបមុខពណ៌ត្នោតក្រហម និងស្នាមពណ៌ត្នោតប្រផេះចាស់នៅផ្នែកខាងក្រោយស្លាប(ចុងស្លាប)។




ដង្កូវចញ្ចឹមខ្លួនដោយស៊ីស្លឹក ប៉ុន្តែ ម្តងម្កាលវាអាចចិញ្ចឹមខ្លួនដោយស៊ីផ្លែខ្ចីៗ។ កូនដង្កូវស៊ីស្លឹកដោយបន្សល់ទុកទ្រនុងស្លឹក។ ដង្កូវធំ ស៊ីចោះជារន្ធមិនស្មើគ្នានៅលើស្លឹក។



មេអំបៅដង្កូវបាក់ខ្នងកប្បាស់



ដង្កូវបាក់ខ្នងកប្បាស់



ដឹកឌឿដង្កូវបាក់ខ្នងកប្បាស់

### ២.១.៣១. ដង្កូវកាត់ដើម

ឈ្មោះទូទៅជាភាសាខ្មែរ : ដង្កូវកាត់ដើម

ឈ្មោះទូទៅជាភាសាអង់គ្លេស : Cutworm

ឈ្មោះវិទ្យាសាស្ត្រ : *Agrotis porphyricollis*

គ្រួសារ : Noctuidae

**ការពិពណ៌នា :**

**ពង:** ពងជាកញ្ចុំដាក់លើស្លឹកដំណាំ ឬស្មៅ ចង្រៃនៅជិតដី។

**មិនទាន់ពេញវ័យ:** ដង្កូវមានប្រវែងចាប់ពី ២៥មម ទៅ ៥០មម។ ដង្កូវកាត់ដើមអាចមានពណ៌ខុសៗគ្នា ប៉ុន្តែជាធម្មតា មានពណ៌ត្នោតប្រផេះចាស់។ ដង្កូវបង្រួញខ្លួន រាងជា អក្សរ "C" នៅពេលមានការរំខាន។

**មេពេញវ័យ:** មេអំបៅមានដងខ្លួនធាត់ ដោយស្លាបមុខមានពណ៌ក្រម៉ៅ។ ស្លាបមុខមានក្រឡា ដែលមានស្នាមអុចស្រាលបីមួយជួរ ផ្ទុយគ្នាពីផ្ទៃខ្មៅ។ ស្លាបក្រោយមានពណ៌ស្លេក។




**ការបំផ្លាញៈ** ដង្កូវធំ កាត់កូនដំណាំស្មើដី បណ្តាល ឱ្យដើមរលំ និងងាប់។



មេអំបៅដង្កូវកាត់ដើម



ពងរបស់ដង្កូវកាត់ដើម



ដង្កូវកាត់ដើម

### ២.១.៣២ ដង្កូវកាត់ដើមទូទៅ

**ឈ្មោះទូទៅជាភាសាខ្មែរ :** ដង្កូវកាត់ដើមទូទៅ

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Common cutworm

**ឈ្មោះវិទ្យាសាស្ត្រ :** *Agrotis infusa*

**គ្រួសារ :** Noctuidae

**ការពិពណ៌នា :**

**ពង:** ពងជាកញ្ចុំដាក់លើស្លឹកដំណាំ ឬស្មៅ ចង្រៃនៅជិតដី

**មិនទាន់ពេញវ័យ:** ដង្កូវមានប្រវែងចាប់ពី ២៥មម ទៅ ៥០មម។ ដង្កូវកាត់ដើមអាចមានពណ៌ខុសៗគ្នា ប៉ុន្តែជាធម្មតា មានពណ៌ត្នោតប្រផេះចាស់។ ដង្កូវបង្រួញខ្លួន រាងជា អក្សរ "C" នៅពេលមានការរំខាន។

**មេពេញវ័យ:** មេអំបៅមានដងខ្លួនធាត់ ដោយស្លាបមុខមានពណ៌ក្រម៉ៅ។ ស្លាបមុខមានក្រឡា ដែលមានស្នាមអុចស្រាលបីមួយជួរ ផ្ទុយគ្នាពីផ្ទៃខ្មៅ។ ស្លាបក្រោយមានពណ៌ស្លេក។

**ការបំផ្លាញ:** បំផ្លាញប៉េងប៉ោះ ប្រភេទដំណាំម្ទេស ម្ទេស និងត្រប់ដង្កូវធំ កាត់កូនដំណាំស្មើដី បណ្តាល ឲ្យដើមរលំ និងងាប់។



ដង្កូវ និងមេអំបៅរបស់វា

### ២.១.៣៣ ដង្កូវខ្មៅកាត់ដើម

**ឈ្មោះទូទៅជាភាសាខ្មែរ :** ដង្កូវខ្មៅកាត់ដើម

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Black cutworm

**ឈ្មោះវិទ្យាសាស្ត្រ :** *Agrotis ipsilon*

**គ្រួសារ :** Noctuidae

**ការពិពណ៌នា :**

**ពង:** ពងជាកញ្ចុំដាក់លើស្លឹកដំណាំ ឬស្មៅ ចង្រៃនៅជិតដី

**មិនទាន់ពេញវ័យ:** ដង្កូវមានប្រវែងចាប់ពី ២៥មម ទៅ ៥០មម។ ដង្កូវកាត់ដើមអាចមានពណ៌ខុសៗគ្នា ប៉ុន្តែជាធម្មតា មានពណ៌ត្នោតប្រផេះចាស់។ ដង្កូវបង្រួញខ្លួន រាងជា អក្សរ "C" នៅពេលមានការរំខាន។

**មេពេញវ័យ:** មេអំបៅមានដងខ្លួនធាត់ ដោយស្លាបមុខមានពណ៌ក្រម៉ៅ។ ស្លាបមុខមានក្រឡា ដែលមានស្នាមអុចស្រាលបីមួយជួរ ផ្ទុយគ្នាពីផ្ទៃខ្មៅ។ ស្លាបក្រោយមានពណ៌ស្លេក។

**ការបំផ្លាញ:** បំផ្លាញប៉េងប៉ោះ ប្រភេទដំណាំម្ទេស ម្ទេស និងត្រប់។ ដង្កូវធំ កាត់កូនដំណាំស្មើដី បណ្តាលឲ្យដើមរលំ និងងាប់។




ដង្កូវ និងមេអំបៅរបស់វា

**២.១.៣៤ ដង្កូវស្មៀតពោត**

**ឈ្មោះទូទៅជាភាសាខ្មែរ :** ដង្កូវស្មៀតពោត

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Corn earworm

**ឈ្មោះវិទ្យាសាស្ត្រ :** *Helicoverpa armigera*

**គ្រួសារ :** Noctuidae

**ការពិពណ៌នា :**

**ពង:** ពងមានរាងក្រឡុប (domes)ពណ៌ស មានអង្កត់តម្រៀបគ្នាដូចឆ្អឹងជំនីដែលមានអង្កត់ផ្ចិត ១មម។ នៅពេលដែលអំប្រីយ៉ុងវិវត្តន៍ ពងប្តូរពណ៌ទៅជាលឿង បន្ទាប់មកពណ៌ទឹកក្រូច និងពណ៌ត្នោតមុនពេលញាស់តែបន្តិច។

**មិនទាន់ពេញវ័យ:** កូនដង្កូវដែលទើបញាស់មានប្រវែង ១,៥មម មានរោម និងពណ៌ក្រែម ដោយមានក្បាលពណ៌ត្នោតក្រម៉ៅ។ ដង្កូវធំអាចមានពណ៌បៃតង ផ្កាឈូក ពណត្នោតព្រលែត ឬត្នោត។ ដង្កូវមានឆ្នូតចំហៀងសម្រាប់សម្គាល់ និងមានរោមមើលឃើញ។

**មេពេញវ័យ:** ពណ៌របស់មេអំបៅអាចខុសៗគ្នា។ ស្លាបមុខ មានពណត្នោតព្រលែត ទៅពណ៌ត្នោតក្រហម ដោយមានស្នាមខ្មៅ។ ស្លាបក្រោយមានពណ៌ ប្រផេះស្លេក ជាមួយខ្សែក្រម៉ៅនៅគែមខាង ក្រោម។

**ការបំផ្លាញ:** ដង្កូវហេលីយ៉ូទីសអាចស៊ីទំពារស្លឹក ឬផ្លែ។ ពួកវាអាចធ្វើឲ្យជ្រុះស្លឹក និងសម្លាប់ដើមនៅក្នុងដំណាក់កាលកូនដំណាំបាន។ ដង្កូវអាច ទំពារបង្កើតជារន្ធក្នុងផ្លែ បង្កឲ្យមានស្នាមជាំ និងបង្កើតរន្ធចូលសម្រាប់កើតជាជំងឺ និងរលួយ។





ដង្កូវ និងមេអំបៅរបស់វា

### ២.១.៣៥ ដង្កូវស៊ីត្រួយ

**ឈ្មោះទូទៅជាភាសាខ្មែរ :** ដង្កូវស៊ីត្រួយ

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Native budworm

**ឈ្មោះវិទ្យាសាស្ត្រ :** *Helicoverpa spp.*

**គ្រួសារ :** Noctuidae

**ការពិពណ៌នា :**

**ពង:** ពងមានរាងក្រឡុប( domes)ពណ៌ស មានអង្កត់តម្រៀបគ្នាដូចឆ្អឹងជំនីដែលមានអង្កត់ផ្ចិត ១មម។ នៅពេលដែលអំប្រីយ៉ុងវិវត្តន៍ ពងប្តូរពណ៌ទៅជាលឿង បន្ទាប់មកពណ៌ទឹកក្រូច និងពណ៌ត្នោតមុនពេលញាស់តែបន្តិច។

**មិនទាន់ពេញវ័យ:** កូនដង្កូវដែលទើបញាស់មានប្រវែង ១,៥មម មានរោម និងពណ៌ក្រែម ដោយមានក្បាលពណ៌ត្នោតក្រម៉ៅ។ ដង្កូវធំអាចមានពណ៌បៃតង ផ្កាឈូក ពណត្នោតព្រលែត ឬត្នោត។ ដង្កូវមានឆ្នូតចំហៀងសម្រាប់សម្គាល់ និងមានរោមមើលឃើញ។

**មេពេញវ័យ:** ពណ៌របស់មេអំបៅអាចខុសៗគ្នា។ ស្លាបមុខ មានពណត្នោតព្រលែត ទៅពណ៌ត្នោតក្រហមដោយមានស្នាមខ្មៅ។ ស្លាបក្រោយមានពណ៌ ប្រផេះស្លេក ជាមួយខ្សែក្រម៉ៅនៅគែមខាង ក្រោម។

**ការបំផ្លាញ:** ដង្កូវហេលីយ៉ូទីសអាចស៊ីទំពារស្លឹក ឬផ្លែ។ ពួកវាអាចធ្វើឲ្យជ្រុះស្លឹក និងសម្លាប់ដើមនៅក្នុងដំណាក់កាលកូនដំណាំបាន។ ដង្កូវអាចទំពារបង្កើតជារន្ធក្នុងផ្លែ បង្កឲ្យមានស្នាមជាំ និងបង្កើតរន្ធចូលសម្រាប់កើតជាជំងឺ និងរលួយ។





ដង្កូវ និងមេអំបៅរបស់វា

### ២.១.៣៦. ដង្កូវស៊ីត្រួយប៉េងប៉ោះ

**ឈ្មោះទូទៅជាភាសាខ្មែរ :** ដង្កូវស៊ីត្រួយប៉េងប៉ោះ

**ឈ្មោះទូទៅជាភាសាអង់គ្លេស :** Tomato budworm

**ឈ្មោះវិទ្យាសាស្ត្រ :** *Helicoverpa punctigera*

**គ្រួសារ :** Noctuidae

ការពិពណ៌នា :

**ពង:** ពងមានរាងក្រឡុប( domes)ពណ៌ស មានអង្កត់តម្រៀបគ្នាដូចឆ្អឹងជំនីដែលមានអង្កត់ផ្ចិត ១មម។ នៅពេលដែលអំប្រីយ៉ុងវិវត្តន៍ ពងប្តូរពណ៌ទៅជាលឿង បន្ទាប់មកពណ៌ទឹកក្រូច និងពណ៌ត្នោតមុនពេលញាស់តែបន្តិច។

**មិនទាន់ពេញវ័យៈ** កូនដង្កូវដែលទើបញាស់មានប្រវែង ១,៥មម មានរោម និងពណ៌ក្រែម ដោយមានក្បាលពណ៌ត្នោតក្រម៉ៅ។ ដង្កូវធំអាចមានពណ៌បៃតង ផ្កាឈូក ពណត្នោតព្រលែត ឬត្នោត។ ដង្កូវមានឆ្នូតចំហៀងសម្រាប់សម្គាល់ និងមានរោមមើលឃើញ។

**មេពេញវ័យៈ** ពណ៌របស់មេអំបៅអាចខុសៗគ្នា។ ស្លាបមុខ មានពណត្នោតព្រលែត ទៅពណ៌ត្នោតក្រហម ដោយមានស្នាមខ្មៅ។ ស្លាបក្រោយមានពណ៌ ប្រផេះស្លេក ជាមួយខ្សែក្រម៉ៅនៅគែមខាង ក្រោម។




ដង្កូវស៊ីត្រួយប៉េងប៉ោះអាចស៊ីទំពារស្លឹក ឬផ្លែ។ ពួកវាអាចធ្វើឱ្យជ្រុះស្លឹក និងសម្លាប់ដើមនៅក្នុងដំណាក់កាលកូនដំណាំបាន។ ដង្កូវអាច ទំពារបង្កើតជារន្ធក្នុងផ្លែ បង្កឱ្យមានស្នាមជាំ និងបង្កើតរន្ធចូលសម្រាប់កើតជាជំងឺ និងរលួយ។



មេអំបៅដង្កូវស៊ីត្រួយប៉េងប៉ោះ



ពងដង្កូវស៊ីត្រួយប៉េងប៉ោះ



ពងដង្កូវស៊ីត្រួយប៉េងប៉ោះជិតញាស់



ការញាស់របស់ដង្កូវស៊ីត្រួយប៉េងប៉ោះជិតញាស់



ពងដង្កូវស៊ីត្រួយប៉េងប៉ោះបំផ្លាញផ្លែ



ដឹកឡើដង្កូវស៊ីត្រួយប៉េងប៉ោះ

### ២.១.៣៧. ដង្កូវបាក់ខ្នង

ឈ្មោះទូទៅជាភាសាខ្មែរ : ដង្កូវបាក់ខ្នង

ឈ្មោះទូទៅជាភាសាអង់គ្លេស : Looper

ឈ្មោះវិទ្យាសាស្ត្រ : *Chrysodeixis acuta, C. chalcites* និង *C. eriosoma*

គ្រួសារ : Noctuidae

ការពិពណ៌នា :

**ពង:** តូច រាងមូល និងមានពណ៌ស្លេក។ ជា ធម្មតា ពងរាយមួយៗ ឬជាកញ្ចុំតូចៗ នៅខាង ក្រោមស្លឹក។

**មិនទាន់ពេញវ័យ:** ដង្កូវមានពណ៌បៃតងស្លេក និងលូតលាស់រហូតដល់ប្រវែង ៤០មម។ វារលោង និងរាងស្រាវ និងធ្វើចលនាជារង្វង់ ឬកោង។

**មេពេញវ័យ:** ស្លាបមុខមានពណ៌ត្នោតក្រម៉ៅ លក្ខណៈជាស្នាមពណ៌ស-ទឹកប្រាក់។




ដង្កូវធ្វើឱ្យចេញគ្រោងឆ្អឹងស្លឹក ឬស៊ី ទំពារបង្កើតជារន្ធ។ ការរុករានក្នុងទ្រង់ទ្រាយធំ អាចធ្វើឱ្យជ្រុះស្លឹកពីដើមបាន។



មេអំបៅដង្កូវបាក់ខ្នង



ដង្កូវបាក់ខ្នង



ដឹកឌឿដង្កូវបាក់ខ្នង

### ២.១.៣៨. ដង្កូវចោះផ្លែពោត

ឈ្មោះទូទៅជាភាសាខ្មែរ : ដង្កូវចោះផ្លែពោត
ឈ្មោះទូទៅជាភាសាអង់គ្លេស : Asian corn borer
ឈ្មោះវិទ្យាសាស្ត្រ : *Ostrinia furnacalis*
គ្រួសារ : Pyralidae

ការពិពណ៌នា :

**ពង:** រាងពងក្រពើ មានពណ៌លឿងខ្ចី ឬពណ៌ ក្រែម ប្រែទៅជាពណ៌ខ្មៅ មុននឹងញាស់។ ពងជាកញ្ចុំគរត្រួតពីលើគ្នា នៅលើស្លឹកខាងលើ និងញាស់ក្នុងរយៈពេល ៣-៥ ថ្ងៃ។

**មិនទាន់ពេញវ័យ:** កូនដង្កូវមានពណ៌ផ្កាឈូក ឬប្រផេះលឿង។ ដង្កូវពេញវ័យមានប្រវែងរហូតដល់៥០មម និងមានពណ៌ស ជាមួយនឹងស្នាមពណ៌ខ្មៅដូចឫស្ស (wart)នៅលើអង្កត់ខ្លួននិមួយៗ។ ដឹកឌឿត្រូវបានប្រទះឃើញនៅកន្លែងដែលដង្កូវស៊ីចំណីចុងក្រោយ។

**មេពេញវ័យ:** មេពេញវ័យមានពណ៌ត្នោត ឬ ពណ៌ចំបើង និងមានសន្ទឹងស្លាបប្រហែល៣០មម។ ក្នុងមួយជីវិតរបស់វា មេអំបៅញីមួយ អាចពងបានរហូតដល់ ១៥០០ពង និងហើរ បាន ១,៥គម។




ការចោះរូងដើមធ្វើឱ្យបាត់បង់ទិន្នផល ដែលបង្កជាចំណុចរលួយទីពីរ និងអាច ធ្វើឱ្យដំណាំដួលលើដី។



មេអំបៅដង្កូវចោះផ្លែពោតអាស៊ី



ដង្កូវចោះផ្លែពោតអាស៊ី



ដង្កូវចោះផ្លែពោតអាស៊ីបំផ្លាញប៉េងប៉ោះ



ដឹកឌឿរបស់ដង្កូវចោះផ្លែពោតអាស៊ី

២.១.៣៩. ដង្កូវរុំស្លឹក

ឈ្មោះទូទៅជាភាសាខ្មែរ : ដង្កូវរុំស្លឹក

ឈ្មោះទូទៅជាភាសាអង់គ្លេស : Beet webworm

ឈ្មោះវិទ្យាសាស្ត្រ : *Spoladea recurvalis*

គ្រួសារ : Pyralidae

ការពិពណ៌នា :

**ពង:** ពណ៌ខៀវ រាងដូចស្រកា និងពងរាយមួយៗ ឬជាគូរ នៅលើផ្ទៃស្លឹកខាងក្រោម។

**មិនទាន់ពេញវ័យ:** កូនដង្កូវមានពណ៌សក្រែម ប៉ុន្តែវិវត្តន៍ទៅពណ៌បៃតងប្រផេះ មានខ្សែខ្មៅសម្គាល់ពីក្រោម ពាក់កណ្តាលខ្នង។ ដង្កូវលូតលាស់ពេញលេញមានប្រវែងប្រហែល២៥មម មានរាងដូចផ្លែរហាត់ និងជាធម្មតាលាតសន្ធឹង ដូច្នេះអាចមើលឃើញជើងទាំងពីរដែលនៅអង្កត់ពោះខាងក្រោយ។ នៅពេលដង្កូវពេញវ័យ វាទម្លាក់ខ្លួនទៅដី និងកាច់សំបុកនាងរាងជាបំពង់ប្រវែងប្រហែល ១២មម នៅក្នុងដីជាប់គល់របស់រុក្ខជាតិ ហើយវាក្លាយ ជាដឹកឌឿនៅពីក្រោមស្រទាប់ផ្ទៃដីនោះ។

**មេពេញវ័យ:** មេអំបៅពេញវ័យមានពណ៌ត្នោតក្រម៉ៅ មានប្រវែង១៩មម និងមានស្លាបលាតចេញ។ ស្លាបមុខមានខ្សែពណ៌សពីរ រាងបញ្ឆិត។ ស្លាបក្រោយចែកដោយខ្សែពណ៌ស រាងបញ្ឆិតធំមួយ។ ស្លាបទាំងពីរមានរាង ត្រីកោណ នៅពេលវាទំសម្រាក។




ជាធម្មតាដង្កូវស៊ីបំផ្លាញស្លឹក ប៉ុន្តែ អាចស៊ីផ្កា និងផ្លែ។ ដង្កូវដំណាក់កាលដំបូងស៊ីបំផ្លាញនៅលើផ្ទៃស្លឹកខាងក្រោម។ ដំណាក់កាលបន្ទាប់ ស៊ីស្លឹកទាំងមូលបន្សល់ទុកតែគ្រោងឆ្អឹងរបស់ស្លឹក និងរុំផ្ទែករបស់ដើមចូលគ្នាហើយស៊ីចិញ្ចឹមខ្លួនវានៅក្នុងនោះ។